**នៅចំពោះមុខអង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

**សំណុំរឿងលេខ:** ០០២/១៩-០៩-២០០៧-អ.វ.ត.ក-អ.ជ.ត.ក

**ភាគីដាក់ឯកសារ:** ក្រុមមេធាវីការពារក្តី នួន ជា

**ដាក់ជូន:** អង្គជំនុំជម្រះតុលាការកំពូល

**ភាសាដើម:** អង់គ្លេស

**កាលបរិច្ឆេទឯកសារ:** ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥

**ចំណាត់ថ្នាក់ឯកសារ**

**ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ:** សាធារណៈ

**ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង:**

**ចំណាត់ថ្នាក់ប្រភេទឯកសារ:**

**ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្តោះអាសន្ន:**

**ឈ្មោះមន្ត្រីកត់ត្រា:**

**ហត្ថលេខា:**

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 09-Feb-2015, 10:37
CMS/CFO: Ly Bunloung

# សារណាតបរបស់ នួន ជា ទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រម របស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿងលេខ ០០២/០១

**ដាក់ដោយ:**

**ក្រុមមេធាវីការពារក្តី នួន ជា**

ស៊ុន អរុណ
Victor KOPPE
ព្រុំ ផល្លា
សួន វិសាល
លីវ សុវណ្ណា
Doreen CHEN
Xiaoyang NIE

**ចម្លងជូន:**

**សហជនជាប់ចោទ**

**សហព្រះរាជអាជ្ញា:**

ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី**

ពេជ អង្គ
Marie GUIRAUD

អនុលោមតាមវិធាន ១០៨(៦) នៃវិធានផ្ទៃក្នុង អ.វ.ត.ក និងមាត្រា ៨.៣ នៃសេចក្ដីណែនាំអនុវត្តសម្រាប់ការដាក់ឯកសារនៅ អ.វ.ត.ក សហមេធាវីការពារក្ដី នួន ជា ("មេធាវីការពារក្ដី") សូមដាក់សារណាតបនេះ ("សារណាតប") ទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១៖

## I. ប្រវត្តិនីតិវិធី

1. នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ សហព្រះរាជអាជ្ញាបានដាក់បណ្ដឹងសាទុក្ខរបស់ខ្លួន ប្រឆាំងនឹងសាលក្រម ក្នុងសំណុំរឿង ០០២/០១ ("បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា" ឬ "បណ្ដឹងសាទុក្ខ")[1]។ ពួកគេលើកទឡ្ហីករណ៍ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ក្នុងការអនុវត្តតាមសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះ[2] ដោយបដិសេធមិនអនុវត្តទម្រង់ទូលំទូលាយនៃសហឧក្រិដ្ឋកម្មរួម ("សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣") នៅ អ.វ.ត.ក។ ពួកគេស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូលបញ្ចូលជាថ្មីនូវសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ដែលជាទម្រង់នៃការទទួលខុសត្រូវដែលអាចអនុវត្តបាន។

2. នៅថ្ងៃទី ១ និង ទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានស្នើសុំពេលវេលាបន្ថែម ដើម្បីឆ្លើយតបទៅនឹងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា[3]។ នៅថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤ អង្គជំនុំជម្រះបានទទួលយកសំណើនេះ និងបានកំណត់យកថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៥ ជាកាលបរិច្ឆេទចុង

---

[1] ឯកសារលេខ **F11** "បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿងលេខ ០០២/០១" ចុះថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២០១៤ ("បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា")។

[2] ឯកសារលេខ **E100/6** "សេចក្ដីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម") ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១ ("សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើឧក្រិដ្ឋកម្មរួម") ដោយអនុវត្តតាម ឯកសារលេខ **D97/15/9** "សាលដីកាលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតចំពោះការអនុវត្តសហឧក្រិដ្ឋកម្មរួម (JCE)" ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០១០ ("សេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះលើឧក្រិដ្ឋកម្មរួម")។

[3] ឯកសារលេខ **F12** "សំណើបន្ទាន់របស់មេធាវីការពារក្ដីលោក ខៀវ សំផន សុំពន្យារពេលឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា" ចុះថ្ងៃទី ១ ខែ ធ្នូ ឆ្នាំ ២០១៤។ ឯកសារលេខ **F14** "សំណើបន្ទាន់របស់ នួន ជា សុំពេលវេលាបន្ថែមដើម្បីឆ្លើយតបទៅនឹងសារណាបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា ប្រឆាំងនឹងសាលក្រមនៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ខែ ធ្នូ ឆ្នាំ ២០១៤។

ក្រោយនៃការដាក់ឯកសារនេះ[4]។ នៅថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥ ដោយសារអង្គភាពបកប្រែភាសាបានប្រមើលមើលថា ការបកប្រែជាភាសាខ្មែរចំពោះចម្លើយតបនេះនឹងមិនអាចបញ្ចប់ទៅតាមកាលបរិច្ឆេទចុងក្រោយនេះបាននោះ មេធាវីការពារក្តីក៏បានស្នើសុំដាក់សំណើតបជាភាសាអង់គ្លេសតែមួយសិន ចំពោះសំណៅបកប្រែជាភាសាខ្មែរនឹងដាក់ជូនតាមក្រោយ បន្ទាប់ពីបកប្រែចប់ភ្លាម[5]។ នៅថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥ អង្គជំនុំជម្រះបានទទួលយកសំណើនេះ[6]។

## II. ឧទ្ធិករណ៍

### ក. បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាមិនអាចទទួលយកបាន

3. ដូចបានលើកឡើងខាងលើ សហព្រះរាជអាជ្ញាចោទប្រកាន់ថា អង្គជំនុំជម្រះសាលាដំបូងមានកំហុសលើអង្គច្បាប់ ដោយមិនបានយកមកអនុវត្តនូវសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ក្នុងការវាយតម្លៃពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ នួន ជា[7]។ ទោះជាយ៉ាងណា វិធាន ១០៤(១)(ក), ១០៥(២)(ក) និង ១០៥(៣) ដែលសហព្រះរាជអាជ្ញាបានយកមកសំអាងដើម្បីប្តឹងសាទុក្ខរបស់ខ្លួននោះ[8] ចែងថា កំហុសនានាលើអង្គច្បាប់ដែលអាចប្តឹងសាទុក្ខបាន ដែលមាននៅក្នុងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង គឺកំហុសដែល "នាំឱ្យមោឃៈសាលក្រម"។ ទោះជាយ៉ាងណា សហព្រះរាជអាជ្ញាមិនបានលើកទឡ្ហីករណ៍ថា កំហុសដែលរងការចោទប្រកាន់របស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នាំឱ្យមោឃៈសាលក្រមក្នុងសំណុំរឿង ០០២/០១ ឬផ្នែកណាមួយនៃសាលក្រមនេះទេ។ ការពិត ពួកគេបានប្រកាសជាសាធារណៈថា ពួក

---

[4] ឯកសារលេខ **F13/2** "សេចក្តីសម្រេចលើសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងសាទុក្ខ និងបន្ថែមពេលវេលាដើម្បីដាក់សារណាតប" ចុះថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១៤។

[5] សារអេឡិចត្រូនិកពីមន្ត្រីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់មេធាវីការពារក្តីផ្ញើជូនអង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៥។

[6] សារអេឡិចត្រូនិកពីមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះតុលាការផ្ញើជូនមន្ត្រីប្រឹក្សាច្បាប់ជាន់ខ្ពស់របស់មេធាវីការពារក្តី ចុះថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៥។

[7] ឯកសារ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។

[8] វិធានទាំងនេះរួមមាន "១០៤, ១០៥, ១០៦, ១០៧ និង ១០៨(១)៖ *សូមមើល* ឯកសារ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១។

គេប្ដឹងសាទុក្ខក្នុងគោលបំណងឲ្យមាន*ការជំនុំជម្រះបន្ថែមទៀត*៩។ និយាយរួម កំហុសដែលបានលើកឡើងមិនស្របទៅនឹងលក្ខខណ្ឌតម្រូវរបស់វិធានផ្ទៃក្នុងទេ។

4. ទោះបីមិនមានចែងច្បាស់នៅក្នុងវិធានផ្ទៃក្នុងក៏ដោយ ក៏វិធានទាំងនេះបង្ហាញថា អង្គជំនុំជម្រះតុលាការកំពូលមានយុត្តាធិការលើកំហុសអង្គច្បាប់ "ដែលមិនត្រឹមតែមិនធ្វើឲ្យសាលក្រមមោឃៈប៉ុណ្ណោះនោះទេ ប៉ុន្តែថែមទាំងមានភាពចាំបាច់ដល់យុត្តិសាស្ត្ររបស់ អ.វ.ត.ក ទៀតផង"[10]។ នៅក្នុងសេចក្ដីជូនដំណឹងពីបណ្ដឹងសាទុក្ខ ("សេចក្ដីជូនដំណឹង") របស់ខ្លួន សហព្រះរាជអាជ្ញាបានជូនដំណឹងថានឹងដាក់បណ្ដឹងសាទុក្ខ "ដើម្បីជាផលប្រយោជន៍ដល់ច្បាប់"[11]។ ទោះជាយ៉ាងណា ពួកគេមិនបានចង្អុលបង្ហាញឲ្យច្បាស់លាស់ថា ការលើកឡើងបែបនេះមានគោលបំណងធ្វើជាមូលដ្ឋានសម្រាប់បង្ហាញថា កំហុសរបស់អង្គជំនុំជម្រះសាលាដំបូងពាក់ព័ន្ធនឹងសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ បានបង្កើតជាកំហុសលើអង្គច្បាប់ចំពោះ "សារៈសំខាន់ចំពោះយុត្តិសាស្ត្ររបស់ អ.វ.ត.ក" ទេ។ សហព្រះរាជអាជ្ញាក៏មិនបានផ្ដល់ការពន្យល់ច្បាស់លាស់ណាមួយស្ដីពីបញ្ហានេះ ទាំងក្នុងបណ្ដឹងសាទុក្ខ ឬទាំងក្នុងសេចក្ដីជូនដំណឹងរបស់ខ្លួនទេ។ ទោះជាយ៉ាងណា ក្នុងករណីនេះ នៅក្នុងការសន្មតថា សហព្រះរាជអាជ្ញាបានលើកទឡ្ហីករណ៍ថា ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ គឺជាបញ្ហាចំពោះ "សារៈសំខាន់នៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក" ក៏ដោយ ក៏ទឡ្ហីករណ៍នេះមិនត្រឹមត្រូវដែរ។ ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ត្រូវបានជំទាស់តវ៉ាអស់ពេលដ៏យូរនៅ អ.វ.ត.ក ក្នុងបរិបទនៃសំណុំរឿង ០០២។ ទោះបីក្នុងពេលមួយ វាជាបញ្ហាចំពោះ "សារៈសំខាន់នៃយុត្តិសាស្ត្ររបស់ អ.វ.ត.ក" ដែលអាចឲ្យអង្គជំនុំជម្រះតុលាការកំពូលយកទៅពិចារណាក៏ដោយ ក៏សារៈសំខាន់បែបនេះក្នុងសំណុំរឿង ០០២ ត្រូវបានលុបបំបាត់តាំងពីយូរមកហើយ។ ហេតុនេះ កំហុសដែលសហព្រះរាជអាជ្ញាបានលើកឡើង មិនមែនជាប្រភេទកំហុសដែលអង្គជំនុំជម្រះតុលាការកំពូលទទួលយកដោយសមរម្យបានទេ ហើយវាគួរតែត្រូវបានប្រកាសថាមិនអាចទទួលយកបានទេ។

---

9 Holly Robertson "បណ្ដឹងសាទុក្ខរបស់អយ្យការនៅសាលាក្ដីខ្មែរក្រហមដើម្បីពង្រីកវិសាលភាព" *កាសែតខេមបូឌា ដេលី* ចុះថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤។

10 សំណុំរឿង ០០១ ឯកសារ **F28** "សាលដីកាលើរឿងក្ដី កាំង ហ្គេកអ៊ាវ" សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជតក ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៥។

11 ឯកសារលេខ **E313/3/1** "សេចក្ដីជូនដំណឹងរបស់សហព្រះរាជអាជ្ញា ស្ដីពីបណ្ដឹងសាទុក្ខចំពោះសេចក្ដីសម្រេច នៅក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ កថាខណ្ឌ ២។

5. ទោះបីជាអង្គជំនុំជម្រះតុលាការកំពូលទទួលយកបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាក៏ដោយ ក៏មេធាវីការពារក្តីលើកឡើងថា បណ្តឹងសាទុក្ខនោះគួរតែត្រូវបានបដិសេធចោល ដោយសារសំអាងហេតុនានាដែលនឹងត្រូវពន្យល់លម្អិតដូចខាងក្រោម។

## ខ. គោលការណ៍នីត្យានុកូលភាពអនុវត្តចំពោះទម្រង់នៃការទទួលខុសត្រូវ

6. នៅក្នុងបណ្តឹងសាទុក្ខរបស់ខ្លួន សហព្រះរាជអាជ្ញាអះអាងថា នៅក្នុងការវិភាគទៅលើភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ អង្គបុរេជំនុំជម្រះ "បានអនុវត្តមិនត្រឹមត្រូវជាមូលដ្ឋាន" នូវគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* ដែលគេស្គាល់ថាជាគោលការណ៍នីត្យានុកូលភាព[12]។ ទោះជាយ៉ាងណា គឺសហព្រះរាជអាជ្ញាទេជាអ្នកយល់ខុស។ ពួកគេជំទាស់ដោយមិនត្រឹមត្រូវថា គោលការណ៍នីត្យានុកូលភាពមិនបានរារាំងតុលាការមិនឱ្យអនុវត្តសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ទេ ដោយសារគោលការណ៍នេះមិនត្រឹមតែពាក់ព័ន្ធនឹងថាតើ "ការប្រព្រឹត្តិ" ដែលជនម្នាក់ត្រូវបានផ្តន្ទាទោសគឺជាការប្រព្រឹត្តិបទឧក្រិដ្ឋដែរ ឬយ៉ាងណា នៅឯពេលវេលាដែលពាក់ព័ន្ធ មិនមែនថាតើ ទម្រង់នៃការទទួលខុសត្រូវដែលបុគ្គលម្នាក់ត្រូវបានផ្តន្ទាទោស "ត្រូវបានកំណត់ដោយធាតុផ្សំដូចគ្នាដែរ ឬយ៉ាងណា នៅពេលដែលមានការប្រព្រឹត្តិអំពើនោះ"[13]។ ពួកគេក៏បានផ្តល់យោបល់ដោយមិនត្រឹមត្រូវថា ទោះបីវាជាទម្រង់នៃការទទួលខុសត្រូវដាច់តែឯងក៏ដោយ តែសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ គឺគ្រាន់តែជា "ការវិវត្តន៍តាមធម្មជាតិ" នៃនិយមន័យសហឧក្រិដ្ឋកម្មរួម ដែលកើតចេញពី "ការបញ្ជាក់បំភ្លឺបន្តិចម្តងៗ" អំពីវិធាននានាតាមរយៈការបកស្រាយរបស់តុលាការ[14]។ ពេលនោះ សហព្រះរាជអាជ្ញាផ្អែកលើកំហុសទាំងនេះ ដើម្បីចោទប្រកាន់ដោយភាន់ច្រឡំថា "ចំពោះគោលបំណងនៃគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង (nullum crimen sine lege)* វាគ្មានភាពចាំបាច់នោះឡើយ ក្នុងការពិចារណាថាតើ ការទទួលខុសត្រូវចំពោះសហឧក្រិដ្ឋកម្មរួម ដូចដែលមានចែងក្នុង [...] មុនឆ្នាំ ១៩៧៥ បានពង្រីកដល់ [...] សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣"[15] ដោយសារ "ការប្រព្រឹត្តិដែលជាលក្ខខណ្ឌតម្រូវសម្រាប់សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ដូចគ្នាបេះបិទទៅនឹងការប្រព្រឹត្តិដែលជាលក្ខខណ្ឌតម្រូវសម្រាប់

[12] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៣។

[13] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៦។

[14] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧ ដល់ ១៨, ២១ ដល់ ២២។

[15] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២២។

សហឧក្រិដ្ឋកម្មរួម ទម្រង់ទី១" សហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ ត្រូវបានចាត់ទុកថាអាចអនុវត្តបាន នៅ អ.វ.ត.ក[16]។ ហេតុនេះ ចំពោះសហព្រះរាជអាជ្ញា "ការអនុវត្តសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ អាចមិនធ្វើឲ្យជនជាប់ចោទដែលទទួលខុសត្រូវព្រហ្មទណ្ឌ ក្នុងករណីដែលគាត់មិនត្រូវទទួលខុសត្រូវ" ក្រោមសហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ ទោះបី "អាចធ្វើឲ្យជនជាប់ចោទនោះទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋច្រើន ដោយផ្អែកលើការប្រព្រឹត្តិបទឧក្រិដ្ឋដូចគ្នា" ក៏ដោយ[17]។

7. ភាពសមហេតុសមផលពីក្រោយគោលការណ៍នីត្យានុកូលភាព ដែលជាគោលការណ៍មូលដ្ឋានមួយរបស់នីតិរដ្ឋ គឺថា "បុគ្គលត្រូវតែទទួលបានការការពារប្រឆាំងនឹងអំណាចរដ្ឋាភិបាលដែលមិនត្រឹមត្រូវ និងការផ្លាស់ប្តូរគំនិតអវិភាពរបស់មនុស្សភាគច្រើន"[18]។ ដូចដែលតុលាការ ECtHR បានលើកមកបញ្ជាក់ថា វាជាការសំខាន់ដែលថា គោលការណ៍សិទ្ធិមនុស្ស "ត្រូវបានបកស្រាយ និងអនុវត្តទៅតាមលក្ខណៈមួយដែលផ្តល់ការធានាឲ្យអាចអនុវត្តជាក់ស្តែង និងមានប្រសិទ្ធភាព និងមិនមែនលក្ខណៈជាទ្រឹស្តី និងបែបបំភាន់ភ្នែកទេ"[19]។ ក្នុងន័យនេះ តុលាការ ECtHR តម្រូវជាពិសេសថា គោលការណ៍នីត្យានុកូលភាព "ត្រូវបានបកស្រាយ និងអនុវត្ត ទៅតាមកម្មវត្ថុ និងគោលបំណងរបស់វា ដើម្បីផ្តល់នូវការការពារយ៉ាងមានប្រសិទ្ធភាពប្រឆាំងនឹងការចោទប្រកាន់ ការផ្តន្ទាទោស និងការដាក់ទណ្ឌកម្ម"[20]។

8. ករណីនេះកើតមាន បន្ទាប់ពីមានលក្ខខណ្ឌតម្រូវឲ្យមាន "ការការពារយ៉ាងមានប្រសិទ្ធភាព" ដែលថា គោលការណ៍នីត្យានុកូលភាពត្រូវផ្តោតទៅលើអ្វីដែលប៉ះពាល់ពិតប្រាកដដល់ជនជាប់ចោទ

---

16 ទោះជាយ៉ាងណា មេធាវីការពារក្តីកត់សម្គាល់ថា ខ្លួនបានប្តឹងសាទុក្ខប្រឆាំងនឹងភាពអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួមទាំងមូល៖ *សូមមើល* ឯកសារលេខ **F16** "បណ្តឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១" ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៤ កថាខណ្ឌ ៤៨៤ ដល់ ៤៩៣។

17 ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤។

18 Antonio Cassese និង អ្នកផ្សេងទៀត *ច្បាប់ព្រហ្មទណ្ឌអន្តរជាតិ៖ រឿងក្តីនានា និងសេចក្តីអធិប្បាយ (International Criminal Law: Cases & Commentary)* (ឆ្នាំ ២០១១) ("Cassese, *រឿងក្តីនានា និងសេចក្តីអធិប្បាយ*") ទំព័រ ៥៣ (ភាសាអង់គ្លេស)។

19 *រឿងក្តី Hirsi Jamaa និង អ្នកផ្សេងទៀត តទល់នឹង ប្រទេសអ៊ីតាលី* "សាលក្រម" តុលាការ ECtHR ពាក្យសុំលេខ 27765/09 ចុះថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ១៧៥ (ភាសាអង់គ្លេស)។

20 *រឿងក្តី Kononov តទល់នឹង ប្រទេសឡាត់វា* "សាលក្រម" តុលាការ ECtHR ពាក្យសុំលេខ 36376/04 ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០១០ កថាខណ្ឌ ១៨៥ (ភាសាអង់គ្លេស)។

ដែលនៅក្នុងរឿងក្តីព្រហ្មទណ្ឌ គឺថាតើ ការប្រព្រឹត្តិរបស់ជនជាប់ចោទនឹងបណ្តាលឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ (និងការដាក់ទណ្ឌកម្ម) ឬយ៉ាងណា។ ចំពោះការប្រព្រឹត្តិដែលបណ្តាលឲ្យមានការទទួលខុសត្រូវព្រហ្មទណ្ឌ ចាំបាច់ត្រូវបង្ហាញនូវទម្រង់នៃការទទួលខុសត្រូវមួយដែលអាចអនុវត្តបាន។ ភាពចាំបាច់នេះត្រូវបានឆ្លុះបញ្ចាំងនៅក្នុងមាត្រា ២៩ នៃច្បាប់ អ.វ.ត.ក ដែលចែងថា មានតែបុគ្គលដែល "មានផែនការញុះញង់ បញ្ជា ប្រព្រឹត្ត ឬជួយនិងជំរុញក្នុងការរៀបចំផែនការ ឬប្រព្រឹត្តិឧក្រិដ្ឋកម្មក្នុងមាត្រា ៣ថ្មី, ៤, ៥, ៦, ៧ និងមាត្រា ៨ នៃច្បាប់នេះត្រូវទទួលខុសត្រូវជាបុគ្គល ចំពោះឧក្រិដ្ឋកម្មនេះ"។ និយាយម្យ៉ាងទៀត ភស្តុតាងនៃទម្រង់នៃការទទួលខុសត្រូវគឺជាជំហានដ៏សំខាន់ តែមិនអាចនាំឲ្យមានការផ្តន្ទាទោសព្រហ្មទណ្ឌទេ។ ហេតុនេះដើម្បីឲ្យគោលការណ៍នីត្យានុកូលភាពអាចក្លាយជា "ការការពារយ៉ាងមានប្រសិទ្ធភាព" ការអនុវត្តនូវគោលការណ៍នេះត្រូវតែពង្រីកឲ្យបានត្រឹមត្រូវចំពោះទម្រង់នៃការទទួលខុសត្រូវ។

9. សហព្រះរាជអាជ្ញាទទួលស្គាល់ថា ការបកស្រាយ និងការអនុវត្តទម្រង់នៃការទទួលខុសត្រូវ ចាំបាច់ត្រូវតែគ្រប់គ្រងដោយគោលការណ៍នីត្យានុកូលភាព។ ហេតុនេះបានជាពួកគេលើកទឡ្ហីករណ៍ថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ មិនមែនជាទម្រង់នៃការទទួលខុសត្រូវដាច់តែឯងទេ តែជាការពង្រីកតាមធម្មជាតិអមដោយការបំភ្លឺបញ្ជាក់បន្តិចម្តងៗ ចំពោះទម្រង់នៃការទទួលខុសត្រូវមួយទៀត គឺសហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ ដែលត្រូវបានចាត់ទុកថាអាចអនុវត្តបាននៅអំឡុងពេលវេលាដែលពាក់ព័ន្ធ។ ជាងនេះទៀត ការខិតខំប្រឹងប្រែងរបស់ពួកគេក្នុងការគាំទ្រដល់ទឡ្ហីករណ៍មិនត្រឹមត្រូវនេះ ដោយបកស្រាយនូវសញ្ញាណនៃ "ការប្រព្រឹត្តិ" យ៉ាងរឹងត្អឹង និងដោយឡែក ដោយមិនគិតដល់ទំនាក់ទំនងរបស់វាទៅនឹងការទទួលខុសត្រូវ គឺជាការប៉ុនប៉ងបំភ្លៃតថភាពធម្មជាតិនៃសំណើរបស់ខ្លួន ដែលការពិតគឺស្នើសុំឲ្យមានការអនុវត្តបែបប្រតិសកម្មទៅលើទម្រង់នៃការទទួលខុសត្រូវដាច់ដោយឡែក ដែលគ្មានអត្ថិភាព ក្នុងអំឡុងពេលដែលពាក់ព័ន្ធទេ។ ទោះជាយ៉ាងណា ពុំមានទឡ្ហីករណ៍ណាមួយក្នុងចំណោមទឡ្ហីករណ៍ទាំងនេះបានជោគជ័យតាមផ្លូវច្បាប់ទេ។

10. ទម្រង់មួយនៃការទទួលខុសត្រូវមួយមិនត្រូវបានកំណត់និយមន័យ ដោយសារតែការប្រព្រឹត្តិរបស់ជនជាប់ចោទមួយមុខទេ។ ទម្រង់នោះក៏រងឥទ្ធិពលពីកត្តាផ្សេងៗទៀត ដូចជា ការប្រព្រឹត្តិរបស់បុគ្គលផ្សេងទៀត ឬទំនាក់ទំនងរវាងការប្រព្រឹត្តិខុសគ្នាតាមរយៈសភាពផ្លូវចិត្តដែលមានពិរុទ្ធភាព ឬចំណងទាក់ទងផ្សេងទៀត។ ហេតុនេះ ការប្រព្រឹត្តិណាមួយរបស់ជនជាប់ចោទតែមួយមុខ មិនអាចយកមកធ្វើជាកត្តាដាច់ខាតក្នុងការសម្រេចថាតើ ទម្រង់នៃការទទួលខុសត្រូវ គឺជាទម្រង់នៃ

ការទទួលខុសត្រូវដាច់តែឯង ឬត្រឹមតែជាផ្នែកមួយដែលមិនអាចផ្តាច់ចេញពីផ្នែកមួយទៀតបានទេ។ ដូច្នេះ ទោះបីការប្រព្រឹត្តិរបស់ជនជាប់ចោទស្ថិតក្រោមសហឧក្រិដ្ឋកម្មរួមទម្រង់ទី១ និង សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ក៏ដោយ ក៏ទម្រង់ទាំងពីរនេះដូចគ្នាបេះបិទ ដែលស្ថិតនៅជាបញ្ហាពោលគឺវាមិនមែនមានន័យថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ មិនមែនជាទម្រង់នៃការទទួលខុសត្រូវដាច់តែឯងទេ។ តាមពិត ដូចដែលសហព្រះរាជអាជ្ញាខ្លួនឯងបានទទួលស្គាល់រួចហើយ[21] សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ អាចពង្រីកមូលដ្ឋានសម្រាប់ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ជនជាប់ចោទ ដើម្បីកំណត់ពីវិសាលភាពនៃការប្រព្រឹត្តិរបស់បុគ្គលផ្សេងទៀត ហើយក្នុងការធ្វើបែបនេះ វាបានលាតសន្ធឹងហួសពីវិសាលភាពនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ ទៅទៀត។ ការណ៍ដែលថា ទោះបីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ និងសហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ អាចបញ្ចូលគ្នានៅក្រោមឆ័ត្ររួមមួយនៃសហឧក្រិដ្ឋកម្មរួម*តាមលក្ខណៈទ្រឹស្តី*ក៏ដោយ តែទម្រង់ទាំងពីរនេះត្រូវតែបានចាត់ទុកថាជាទម្រង់នៃការទទួលខុសត្រូវដាច់ដោយឡែកពីគ្នា ពាក់ព័ន្ធនឹងគោលការណ៍នីត្យានុកូលភាព។

11. ដូចបានលើកឡើងខាងលើ គោលការណ៍នីត្យានុកូលភាពមិនត្រឹមតែពាក់ព័ន្ធនឹងទស្សនៈជាទ្រឹស្តីប៉ុណ្ណោះទេ តែវាពាក់ព័ន្ធនឹងអ្វីដែលអាចប៉ះពាល់ជាក់ស្តែងដល់បុគ្គលណាម្នាក់ទៀត។ ទម្រង់នៃការទទួលខុសត្រូវប៉ះពាល់ដល់បុគ្គលផ្សេងទៀត តាមរយៈការសម្រេច មិនត្រឹមតែទៅលើថាតើមនុស្សម្នាក់អាច ឬមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌប៉ុណ្ណោះទេ តែក៏ចំពោះការសម្រេចទៅលើ*វិសាលភាព និងចំនួន* ឧក្រិដ្ឋកម្មដែលពួកគេអាចទទួលខុសត្រូវ។ ចំពោះបុគ្គលជាជនជាប់ចោទ បញ្ហាវិសាលភាព និងចំនួនឧក្រិដ្ឋកម្ម មានលក្ខណៈដូចគ្នា។ ហេតុនេះ វាជាកំហុសឆ្គងផង និងមិនសមហេតុសមផល ដែលសហព្រះរាជអាជ្ញាផ្តល់យោបល់ថា ដរាបណាមនុស្សណាម្នាក់ប្រព្រឹត្តឧក្រិដ្ឋកម្មមួយដោយចេតនា និងរួមគ្នាដែលស្ថិតក្នុងយុត្តាធិការរបស់ អ.វ.ត.ក ហើយនឹងទទួលខុសត្រូវតាមរយៈសហឧក្រិដ្ឋកម្មរួម ទម្រង់ទី១ ចំពោះឧក្រិដ្ឋកម្ម*នោះ* គេអាចទទួលស្គាល់បានដោយពេញលេញ និង "គ្មានគ្រោះថ្នាក់" ដើម្បីឲ្យបុគ្គលនោះទទួលខុសត្រូវចំពោះ "ឧក្រិដ្ឋកម្មជាច្រើនទៀត" ទោះបីនៅពេលពុំមានទម្រង់នៃការទទួលខុសត្រូវមានចែងក្នុងច្បាប់ដើម្បីភ្ជាប់មនុស្សនេះទៅនឹងឧក្រិដ្ឋកម្មបន្ថែមទាំងនោះក៏ដោយ[22]។ ការលើកឡើងរបស់សហព្រះ

[21] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២១។

[22] ឧទាហរណ៍ ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៤, ២០, ២២។

រាជអាជ្ញានឹងធ្វើឱ្យទម្រង់នៃការទទួលខុសត្រូវទៅជាទម្រង់នៃការបំផ្លើសទាំងស្រុង ដោយមិននិយាយដល់ន័យបញ្ហាសទាំងអស់នៃភាពសមហេតុសមផល និងគោលបំណងរបស់គោលការណ៍នីត្យានុកូលភាព។

12. ការណ៍ដែលសហព្រះរាជអាជ្ញាសំអាងទៅលើ *រឿងក្តី Furundžija* ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនដែលថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ មិនមានអ្វីក្រៅពីការវិវត្តតាមធម្មជាតិនៃនិយមន័យនៃសហឧក្រិដ្ឋកម្មរួម[23] គឺមិនត្រឹមត្រូវទេ។ នៅក្នុង *រឿងក្តី Furundžija* បញ្ហាគឺថាតើ ការរួមភេទតាមមាត់ដោយបង្ខំ ដែលជា "ឧក្រិដ្ឋកម្មមួយក្នុងករណីណាក៏ដោយ" អាចត្រូវបានចោទប្រកាន់ជា "បទល្មើសរំលោភសេពសន្ថវៈ" ឬជា "ការវាយប្រហារផ្លូវភេទ"[24]។ ទោះជាយ៉ាងណា អ្វីដែលជាបញ្ហានៅទីនេះគឺ *មិនមែន*ថាតើ "ការប្រព្រឹត្តិ" ដែលក្លាយជាបទល្មើសព្រហ្មទណ្ឌពិតប្រាកដ ដូចជាការរួមភេទតាមមាត់ដោយបង្ខំ គួរតែត្រូវបានពិពណ៌នាថាជាឧក្រិដ្ឋកម្មនៃ "បទល្មើសរំលោភសេពសន្ថវៈ" ឬជា "ការវាយប្រហារផ្លូវភេទ" ឬទេ។ ផ្ទុយទៅវិញ ក្នុងការបន្ថែមទៅលើករណីដែលជនជាប់ចោទត្រូវបានផ្តន្ទាទោសពីបទល្មើសផ្លូវភេទនេះ បញ្ហានោះគឺថាតើ បុគ្គលដែលបានអនុវត្តការប្រព្រឹត្តិនោះអាចទទួលខុសត្រូវ *ផងដែរ*ចំពោះការសម្លាប់ទៅលើជនរងគ្រោះ ទោះបីបុគ្គលនេះគ្មានចេតនា ឬមិនបានប្រព្រឹត្តអំពើមនុស្សឃាតក៏ដោយ ឬយ៉ាងណា។ ខុសពី *រឿងក្តី Furundžija* ដែលការបង្កើតនិយមន័យនៃបទល្មើសផ្លូវភេទមិនប៉ះពាល់ដល់ *វិសាលភាព*នៃការទទួលខុសត្រូវរបស់បុគ្គល បញ្ហានាពេលនេះពាក់ព័ន្ធនឹងការដាក់បញ្ចូលនូវទម្រង់នៃការទទួលខុសត្រូវមួយដែលពង្រីកវិសាលភាពនោះយ៉ាងធំធេង។ ហេតុនេះ *រឿងក្តី Furundžija* មិនបានផ្តល់ការណែនាំពាក់ព័ន្ធដល់បញ្ហានាពេលនេះទេ។ មេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា ពាក់ព័ន្ធនឹងទំនាក់ទំនងរវាងការបកស្រាយតាមផ្លូវតុលាការ និងគោលការណ៍នីត្យានុកូលភាព តុលាការគួរតែដឹងដោយប្រុងប្រយ័ត្នជានិច្ចថា "ជាញឹកញយ បទឧក្រិដ្ឋអន្តរជាតិ ចម្រាញ់យកតែភាពធូរធ្ងរ និងភាពរន្ធត់ និងការប៉ុនប៉ងធ្វើឱ្យមានភាពស្រពេចស្រពិលរវាងការបកស្រាយតាមផ្លូវតុលាការ និងការបញ្ជាក់ច្បាស់លើវិធានជាធរមាន និង វិសាលភាពប្រតិសកម្មនៃវិធាននានា"[25]។ គេត្រូវពឹង

---

[23] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៧។

[24] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Furundžija* "សាលក្រម" សំណុំរឿងលេខ IT-95-17/1-T ចុះថ្ងៃទី ១០ ខែ ធ្នូ ឆ្នាំ ១៩៩៨ (សាលក្រមអង្គជំនុំជម្រះសាលាដំបូងលើ *រឿងក្តី Furundžija*") កថាខណ្ឌ ១៨៤ (ភាសាអង់គ្លេស)។

[25] Cassese *រឿងក្តីនានា និងសេចក្តីអធិប្បាយ* ទំព័រ ៧៤ (ភាសាអង់គ្លេស)។

ផ្អែកទៅលើតុលាការដែលផ្តន្ទាទោសចំពោះឧក្រិដ្ឋកម្មទាំងនេះ ដើម្បីរក្សានូវការប្រុងប្រយ័ត្ន និងធានាថា ឧក្រិដ្ឋកម្មទាំងនោះគ្មានភាពស្រពេចស្រពិល" ឡើយ។

13. សហព្រះរាជអាជ្ញាក៏បានអះអាងផងដែរថា ភាពធ្ងន់ធ្ងរនៃបទឧក្រិដ្ឋនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក "បានផ្តល់នូវការការពារបន្ថែមទៀតប្រឆាំងនឹងការរំលោភបំពានណាមួយទៅលើគោលការណ៍*គ្មានបទល្មើស បើគ្មានច្បាប់ចែង* (nullum crimen sine lege)" ដោយសារចំណុចនេះរារាំងជនជាប់ចោទមិនឱ្យឆ្លើយថា ខ្លួនមិនបានដឹងថាការប្រព្រឹត្តិរបស់ខ្លួនជាបទឧក្រិដ្ឋនោះទេ[26]។ ទោះជាយ៉ាងណា ជាថ្មីម្តងទៀត ទឡ្ហីករណ៍នេះមិនត្រឹមត្រូវទេ។ ដូចដែលសហព្រះរាជអាជ្ញាបានទទួលស្គាល់ហើយគឺថា យុត្តិសាស្ត្រមានភាពច្បាស់លាស់ថា "អំពើអសីលធម៌ ឬអំពើដែលមានចរិតលក្ខណៈគួរឱ្យរន្ធត់ មិនអាចចាត់ជាកត្តាគ្រប់គ្រាន់ ដើម្បីកំណត់ថាជាបទល្មើសព្រហ្មទណ្ឌទេ"[27]។ ជាងនេះទៀត ទោះបីភាពធ្ងន់ធ្ងរនៃបទល្មើសព្រហ្មទណ្ឌដែលត្រូវបានចោទប្រកាន់ អាចនឹងរារាំងជនជាប់ចោទមិនឱ្យឆ្លើយថា ខ្លួនមិនបានដឹងពីចរិតនៃការប្រព្រឹត្តិរបស់ខ្លួនក៏ដោយ តែវាមិនបានបើកផ្លូវឱ្យតុលាការក្នុងការផ្តន្ទាទោសជនជាប់ចោទ ពីការប្រព្រឹត្តិផ្សេងៗទៀតដែលជាបទល្មើសព្រហ្មទណ្ឌទេ តែប្រហែលជាអាចផ្តាច់វាចេញពីការប្រព្រឹត្តិរបស់ជនជាប់ចោទបាន។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា ក្នុងការវាយតម្លៃពីភាពដែលអាចព្យាករណ៍បាន អ្វីដែលតុលាការគួរតែប្រមើលមើលគឺថា "ប្រសិនបើតុលាការនៅតែតតាំង និងកាច់បំបាក់ទៅលើករណីថាតើច្បាប់អន្តរជាតិបានហាមឃាត់ការប្រព្រឹត្តិនៅពេលដែលវាបានកើតឡើង ឬយ៉ាងណា តើវាមានភាពប្រត្យក្ស ឬយុត្តិធម៌កម្រិតណាដែលលើកឡើងថា ច្បាប់នោះមានភាពជាក់លាក់គ្រប់គ្រាន់ ដើម្បីឱ្យជនជាប់ចោទបានដឹងជាមុនថា ការប្រព្រឹត្តិរបស់ខ្លួនជាបទល្មើសព្រហ្មទណ្ឌនោះ?"[28]។

14. ក្រៅពីដើរតួនាទីជាចំណងទាក់ទងរវាងបទល្មើសព្រហ្មទណ្ឌ និងការទទួលខុសត្រូវនោះ ទម្រង់នៃការទទួលខុសត្រូវក៏ប៉ះពាល់ផងដែរទៅលើបុគ្គលដោយកំណត់និយមន័យអំពី*ចរិត និងកម្រិត*នៃការទទួលខុសត្រូវរបស់ពួកគេ។ តើមនុស្សម្នាក់ទទួលខុសត្រូវក្នុងនាមជាអាទិចារីដែលបានអនុវត្តដោយផ្ទាល់នូវបទល្មើសព្រហ្មទណ្ឌ ឬជាចារីបន្ទាប់បន្សំដែលបានជួយនិងជំរុញ មិនមែនត្រឹមតែជា

---

[26] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩ ដល់ ២០។

[27] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៩។ *សំណុំរឿង ០០១* ឯកសារ **F28** "សាលដីកា" សំណុំរឿងលេខ ០០១/១៨ កក្កដា ២០០៧/អវតក/អជតក ចុះថ្ងៃទី ៣ ខែ កុម្ភៈ ឆ្នាំ ២០១២ កថាខណ្ឌ ៩០។

[28] Cassese *រឿងក្តីទាន់ និងសេចក្តីអធិប្បាយ* ទំព័រ ៧៤ (ភាសាអង់គ្លេស)។

បញ្ហានៃភាពច្បាស់លាស់ក្នុងការពិពណ៌នាប៉ុណ្ណោះទេ តែជាការចែករំលែកនូវការទទួលខុសត្រូវដោយត្រឹមត្រូវ ឬយ៉ាងណា[29]។ ទម្រង់ខុសៗគ្នានៃការទទួលខុសត្រូវចង្អុលបង្ហាញពីចរិត និងកម្រិតខុសៗគ្នានៃការទទួលខុសត្រូវ ដែលជាធម្មតានាំឱ្យមានការដាក់ទណ្ឌកម្មក៏ខុសៗគ្នាដែរ។ ទោះបីមិនប៉ះពាល់ដល់ការដាក់ទណ្ឌកម្មក៏ដោយ តែការពិពណ៌នាអំពីចរិត និងកម្រិតនៃការទទួលខុសត្រូវរបស់ជនណាម្នាក់មានជាប់មកជាមួយនឹងស្លាកស្នាមទុយ៌ស និងការថ្កោលទោសពីសង្គម ដែលបង្កជាបញ្ហាដល់បុគ្គលមិនចាញ់ការផ្តន្ទាទោសប៉ុន្មានទេ។ ផលប៉ះពាល់ពីទម្រង់នៃការទទួលខុសត្រូវនានានេះ មិនទាន់ក្លាយជាសំអាងហេតុមួយផ្សេងទៀតដែលនាំឱ្យទម្រង់នៃការទទួលខុសត្រូវទាំងនោះត្រូវគ្រប់គ្រងដោយគោលការណ៍នីត្យានុកូលភាពទេ៖ ដើម្បីការពារបុគ្គលប្រឆាំងនឹងការដាក់បញ្ចូលទម្រង់នៃការទទួលខុសត្រូវបែបប្រតិសកម្ម ដោយមិនត្រឹមត្រូវ ដែលអាចបណ្តាលឱ្យបុគ្គលទាំងនោះត្រូវទទួលខុសត្រូវដោយអយុត្តិធម៌ក្នុងកម្រិតធ្ងន់ធ្ងរជាងមុន។

15. ក្នុងន័យនេះ ជាការសមរម្យដែលត្រូវបង្ហាញថា រាល់សំអាងហេតុទាំងអស់ដែលអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុង*រឿងក្តី Tadić* បានដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមគឺថា តុលាការនេះមានកង្វល់ថា ក្នុងកាលៈទេសៈខ្លះ “ដើម្បីឱ្យ [បុគ្គលមួយចំនួន] ទទួលខុសត្រូវត្រឹមតែជាអ្នកជួយនិងជំរុញ ដែលធ្វើឱ្យកម្រិតនៃការទទួលខុសត្រូវនូវបទព្រហ្មទណ្ឌរបស់ខ្លួនមានការថមថយ”។ ដំណោះស្រាយក្នុងគំនិតរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY គឺថា សហឧក្រិដ្ឋកម្មរួមនឹងដោះស្រាយបញ្ហានេះ ដោយជំរុញឱ្យតុលាការកំណត់ថា បុគ្គលទាំងនោះត្រូវទទួលខុសត្រូវក្នុងនាមជា (សហ)ចារី[30]។ ទោះជាយ៉ាងណា ចំណុចនេះមិនមែនជាសំអាងហេតុច្បាស់លាស់ដែលថា សហឧក្រិដ្ឋកម្មរួម *មិន*គួរត្រូវបានដាក់បញ្ចូលទេ៖ ការដាក់បញ្ចូលសហឧក្រិដ្ឋកម្មរួមរំលោភទៅលើច្បាប់ជាធរមាន នៅពេលដែលច្បាប់មិនបានគាំទ្រដល់ទម្រង់នៃការទទួលខុសត្រូវ

---

[29] Antonio Cassese *គូកន Oxford នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ (The Oxford Companion to International Criminal Justice)* (ឆ្នាំ២០០៩) (“Cassese *តុលាការព្រហ្មទណ្ឌអន្តរជាតិ*”) ទំព័រ ៥៩ (ភាសាអង់គ្លេស)។

[30] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Tadić* “សាលដីកា” សំណុំរឿងលេខ IT-94-1-A ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ១៩៩៩ (“សាលដីកាបណ្តឹងសាទុក្ខលើ*រឿងក្តី Tadić*”) កថាខណ្ឌ ១៩២ (ភាសាអង់គ្លេស)។ *សូមមើលផងដែរ* Cassese *តុលាការព្រហ្មទណ្ឌអន្តរជាតិ* ទំព័រ ៥៥ (ភាសាអង់គ្លេស) “បទដ្ឋាននៃពិរុទ្ធភាពរបស់បុគ្គលគួរតែត្រូវបានអង្កេតដោយយកចិត្តទុកដាក់ដើម្បីចៀសវាងការចូលរួមចំណែកក្នុងការទទួលខុសត្រូវមិនពេញលេញ។ ឧទាហរណ៍ នៅទីនេះ ប្រភេទទីបីនៃសហឧក្រិដ្ឋកម្មរួមគឺជាបញ្ហាសំខាន់”។

ដែលមានការពង្រីកដូចនេះ[31]។

## គ. ប្រភពច្បាប់អន្តរជាតិ និងតួនាទីរបស់ច្បាប់ក្នុងស្រុក

16. សហព្រះរាជអាជ្ញាទទួលស្គាល់ថា ទាំងអង្គជំនុំជម្រះសាលាដំបូង និងអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុង*រឿងក្តី Tadić* បានកំហិតគោលបំណងនៃការពិនិត្យរបស់ខ្លួនទៅលើច្បាប់ជាតិ និងយុត្តិសាស្ត្រត្រឹមតែការកំណត់ពីអត្ថិភាពនៃគោលការណ៍ទូទៅដែលអាច ឬមិនអាចគាំទ្រដល់ភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម[32]។ ទោះជាយ៉ាងណា ពួកគេអះអាងថា វិធីសាស្ត្រនេះមិនត្រឹមត្រូវទេ ដោយសារ បន្ថែមទៅលើការបង្ហាញគោលការណ៍ទូទៅ ច្បាប់ជាតិ និងយុត្តិសាស្ត្រក៏អាចដើរតួនាទីជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិផងដែរ ហើយថា ខុសពីគោលការណ៍ទូទៅ ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនតម្រូវឲ្យមានការឯកភាពជាកម្រិតខ្ពស់នៃទម្លាប់អនុវត្តរបស់រដ្ឋឡើយ។ ហេតុនេះ សហព្រះរាជអាជ្ញាដែលអះអាងថា សហឧក្រិដ្ឋកម្មរួមជាវិធាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិ មិនមែនជាគោលការណ៍ទូទៅមួយនោះ[33] បង្ហាញថា ដោយមិនចាំបាច់បញ្ជាក់ថា "ប្រទេសភាគច្រើន ប្រសិនបើមិនបានទាំងអស់" បានទទួលយកសញ្ញាណដូចគ្នានៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ទេ[34]។

### *(i) តួនាទីរបស់ច្បាប់ក្នុងស្រុក*

17. សហព្រះរាជអាជ្ញាអះអាងយ៉ាងត្រឹមត្រូវថា ការបង្កើតគោលការណ៍រួមមួយតម្រូវឲ្យមានភស្តុតាងនៃការទទួលយកគោលការណ៍នោះ ដោយ "ប្រទេសភាគច្រើន ប្រសិនបើមិនបានទាំងអស់" ហើយថា នេះជាការឯកភាពកម្រិតខ្ពស់ជាងអ្វីដែលតម្រូវដើម្បីបង្កើតច្បាប់ទំនៀមទម្លាប់អន្តរជាតិ។ ទោះជាយ៉ាងណា ពួកគេមានកំហុសក្នុងការប្រព្រឹត្តិចំពោះច្បាប់ក្នុងស្រុកដែលជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

18. ដូចដែលអង្គបុរេជំនុំជម្រះបានសម្រេចយ៉ាងត្រឹមត្រូវ "ករណីទាំងនេះ ដែលតុលាការក្នុងស្រុកនានា

---

[31] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Brđanin* "សាលដីកា" សំណុំរឿងលេខ IT-99-36-A ចុះថ្ងៃទី ៣ ខែ មេសា ឆ្នាំ ២០០៧ កថាខណ្ឌ ៤៣០ (ភាសាអង់គ្លេស)។

[32] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៣ ដល់ ៤៤។

[33] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៤។

[34] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៤ ដល់ ៤៨។

បានអនុវត្តច្បាប់*ក្នុងស្រុក* មិនចាត់ទុកជាយុត្តិសាស្ត្រ*អន្តរជាតិ*ឡើយ" ហើយមិនគួរត្រូវបានចាត់ទុកថាជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិទេ[35]។ សំអាងហេតុគឺមានភាពត្រង់ៗតែម្តង៖ "គេមិនអាចសន្មតថា តុលាការក្នុងស្រុកអនុវត្តច្បាប់[ក្នុងស្រុក] ដោយមានសញ្ញាណដែលគិតទុកជាមុនថា វិធាននានាដែលខ្លួនកំពុងអនុវត្តគឺត្រូវបានតម្រូវ ឬបានអនុញ្ញាតដោយច្បាប់ទំនៀមទម្លាប់អន្តរជាតិ"[36]។ ប្រសិនបើ ការណ៍ដែលតុលាការក្នុងស្រុកអនុវត្តច្បាប់ក្នុងស្រុកអាចត្រូវបានពិចារណាថាជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ វាមិនសមទំនងទេ ដែលថាអំពើមនុស្សឃាត អំពើលួច និងបទល្មើសធម្មតាគ្រប់ប្រភេទនឹងក្លាយជាបទឧក្រិដ្ឋតាមច្បាប់អន្តរជាតិហើយ។

19. ហេតុនេះ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា អ.វ.ត.ក[37] និង តុលាការ ICTY[38] បានបែងចែកដាច់ពីគ្នាយ៉ាងត្រឹមត្រូវរវាង ការអនុវត្តច្បាប់*អន្តរជាតិ*របស់តុលាការក្នុងស្រុក (ឧទាហរណ៍ ការជំនុំជម្រះក្តីនានាទៅតាម ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង) និងការអនុវត្តច្បាប់*ក្នុងស្រុក*របស់តុលាការក្នុងស្រុក ដោយគ្រាន់តែពិនិត្យទៅលើការអនុវត្តច្បាប់អន្តរជាតិក្នុងការសម្រេចរបស់ខ្លួនចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិ និងកំហិតការពិនិត្យទៅលើការអនុវត្តច្បាប់ក្នុងស្រុក ក្នុងគោលបំណងតែមួយគត់គឺបង្កើតគោលការណ៍ទូទៅ។

20. បន្ថែមលើការលើកឡើងដោយមិនត្រឹមត្រូវដែលថា យុត្តិសាស្ត្ររបស់តុលាការក្នុងស្រុកទៅលើច្បាប់ក្នុងស្រុក អាចយកមកសំអាងជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាក្នុងន័យនេះក៏មានកំហុសឆ្គងផងដែរ ក្នុងការធ្វើឲ្យច្របូកច្របល់នូវទស្សនៈរបស់ច្បាប់ទំនៀមទម្លាប់អន្តរជាតិជាមួយនឹងទស្សនៈនៃគោលការណ៍ទូទៅ។ នៅក្នុងការខិតខំប្រឹងប្រែងពន្យល់ពីរបៀបរកឲ្យឃើញនូវទម្លាប់អនុវត្តរបស់រដ្ឋ ក្នុងគោលបំណងកំណត់

[35] ឯកសារលេខ **D97/15/9** សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២ (គូសបញ្ជាក់បន្ថែម")។

[36] G. Boas និង W. Schabas *ការវិវត្តនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិក្នុងច្បាប់យុត្តិសាស្ត្ររបស់តុលាការ (International Criminal Law Developments in the Case Law of the ICTY)* (ឆ្នាំ ២០០៣) ២៨៣។

[37] ឯកសារលេខ **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧។ ឯកសារលេខ **D97/15/9** សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨២។

[38] សាលដីកាបណ្តឹងសាទុក្ខលើ*រឿងក្តី Tadić* កថាខណ្ឌ ២២៥ (ភាសាអង់គ្លេស)។ សាលក្រមលើ*រឿងក្តី Furundžija* កថាខណ្ឌ ១៩៦ (ភាសាអង់គ្លេស) "ច្បាប់ដែលយកមកអនុវត្តជាច្បាប់ក្នុងស្រុក ហេតុនេះការចេញប្រកាសសាលក្រមរបស់តុលាការនៅចក្រភពអង់គ្លេសមិនបានគួរក្នុងការបង្កើតវិធាននៃច្បាប់អន្តរជាតិលើបញ្ហានេះប៉ុន្មានទេ"។

អត្ថសញ្ញាណច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ សហព្រះរាជអាជ្ញាក៏អះអាងថា "នៅពេលធ្វើការវាយតម្លៃពីទម្លាប់នៃការអនុវត្តរបស់រដ្ឋណាមួយ គេត្រូវសួរថាតើមានការគាំទ្រចំពោះអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ដែរឬអត់នោះ កត្តាសម្រេចគឺថាតើផ្នែកស្នូល និង*គោលការណ៍ជាមូលដ្ឋាន*នៃទស្សនៈ [...] មាននៅក្នុងបញ្ញត្តិ និងយុត្តិសាស្ត្រច្បាប់ជាធរមានរបស់រដ្ឋនោះដែរឬទេ"[39]។ ទោះជាយ៉ាងណាក្តី ការពិត វិធីសាស្ត្រនេះដែលត្រូវបានពិពណ៌នាដោយសហព្រះរាជអាជ្ញាគឺជាវិធីសាស្ត្រសម្រាប់កំណត់អត្តសញ្ញាណ*គោលការណ៍ទូទៅ* ជាងច្បាប់ទំនៀមទម្លាប់អន្តរជាតិ[40]។ "វិធាន" នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិខុសគ្នាជាសារវ័ន្តពី "គោលការណ៍" ទូទៅ[41]។ សហព្រះរាជអាជ្ញាមិនបានទទួលស្គាល់នូវភាពខុសគ្នានេះទេ។

### *(ii) គោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់ ដោយបណ្តាប្រជាជាតិនៅទូទាំងពិភពលោក*

21. ពាក់ព័ន្ធនឹងគោលការណ៍ទូទៅដែលជាប្រភពច្បាប់អន្តរជាតិវិញ មេធាវីការពារក្តីសូមលើកឡើងពីរចំណុច។ ទីមួយ មានឋានានុក្រមមួយនៅក្នុងប្រភពច្បាប់អន្តរជាតិដែលអាចអនុវត្តបាននៅក្នុងការជំនុំជម្រះក្តីបទឧក្រិដ្ឋអន្តរជាតិ អនុលោមតាមគោលការណ៍ទូទៅរបស់ច្បាប់ព្រហ្មទណ្ឌដែលត្រូវបានទទួលស្គាល់ដោយប្រព័ន្ធច្បាប់ក្នុងស្រុករបស់បណ្តាប្រជាជាតិនៅលើពិភពលោក គឺជាការសម្រេចចុងក្រោយ។ ហេតុនេះ គោលការណ៍ទូទៅនានាត្រឹមតែអាចយកមកសំអាងបាន នៅពេលដែលទាំងសន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌអន្តរជាតិ (ដូចជាគោលការណ៍នីត្យានុកូលភាព) មិនបានផ្តល់ការណែនាំឲ្យបានពេញលេញ[42]។ តុលាការ ICJ បានលើកឡើងនៅក្នុង*រឿងក្តី Barcelona Traction* ថា ដើម្បីឲ្យតុលាការអន្តរជាតិយកច្បាប់

---

[39] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤៩។

[40] *រឿងក្តី រដ្ឋអាជ្ញា តទល់នឹង Erdemović* "មតិយោបល់ដោយឡែករួមរបស់ចៅក្រម Mcdonald និងចៅក្រម Vohrah" សំណុំរឿងលេខ IT-96-22-A ចុះថ្ងៃទី ៧ ខែ តុលា ឆ្នាំ ១៩៩៧ ("*រឿងក្តី Erdemović* មតិយោបល់ដោយឡែករួម") កថាខណ្ឌ ៥៧ (ភាសាអង់គ្លេស) ""គោលការណ៍ទូទៅ" មិនត្រូវឲ្យច្រឡូកច្រល់ជាមួយនឹងការបង្ហាញដ៏រឹងមាំរបស់គោលការណ៍នោះនៅក្នុងវិធានជាក់លាក់ទេ [...] វិធីសាស្ត្ររបស់យើងនឹងមិនចាំបាច់ចូលរួមពាក់ព័ន្ធចូលរួមក្នុងការប្រៀបធៀបដោយផ្ទាល់របស់វិធានជាក់លាក់ទេ [...] តែផ្ទុយទៅវិញ គឺចូលរួមក្នុងការស្ទាបស្ទង់មតិ [...] ក្នុងកិច្ចខិតខំប្រឹងប្រែងដើម្បីយល់ឲ្យបាននូវចរន្ត គោលនយោបាយ ឬគោលការណ៍ទូទៅមួយដែលនៅពីក្រោមវិធានរឹងមាំ"។

[41] *រឿងក្តី Erdemović* មតិយោបល់ដោយឡែករួម កថាខណ្ឌ ៥៧ (ភាសាអង់គ្លេស)។

[42] Cassese *រឿងក្តីនានា និងសេចក្តីអធិប្បាយ* ទំព័រ ៣៤ ដល់ ៣៥ (ភាសាអង់គ្លេស)។

ជាតិមកសំអាងបានដោយត្រឹមត្រូវ ចាំបាច់ត្រូវ "គ្មានការបញ្ចូលច្បាប់អន្តរជាតិដែលតុលាការអាចយកមកសំអាងបាន"[43]។ មាត្រា២១(១)(គ) នៃលក្ខន្តិកៈទីក្រុងរ៉ូមបានគាំទ្រវិធីសាស្ត្រដូចគ្នានេះ ដែលចែងថា គ្រាន់តែ "មិនបាន" កំណត់អត្តសញ្ញាណ ច្បាប់អន្តរជាតិជាធរមាននានា តុលាការនោះអាចយកមកសំអាងបាន ចំពោះគោលការណ៍ទូទៅនានាដែលដកចេញពីច្បាប់ក្នុងស្រុក។ លទ្ធផលនៃឋានានុក្រមនេះគឺថា ដរាបណាអាចរកចម្លើយនៅក្នុងសន្ធិសញ្ញា ច្បាប់ទំនៀមទម្លាប់អន្តរជាតិ ឬគោលការណ៍ទូទៅនៃច្បាប់ព្រហ្មទណ្ឌ អន្តរជាតិបាន វាមិនចាំបាច់ និងមិនសមរម្យទេ ដែលតុលាការផ្តល់ទំនុកចិត្តលើយុត្តិធម៌អន្តរជាតិ ដើម្បីសំអាងទៅលើច្បាប់ក្នុងស្រុក ទោះបីនៅពេលដែលការសំអាងនេះមានគោលបំណងដកចេញនូវ*គោលការណ៍*រួម ជាជាងផ្លាស់ប្តូរដោយផ្ទាល់នូវ*វិធាន*ជាក់លាក់ទាំងនេះក៏ដោយ។

22. ទីពីរ ខុសពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ គោលការណ៍ទូទៅតម្រូវឱ្យមានការឯកភាពកម្រិតខ្ពស់នៃច្បាប់ក្នុងស្រុក។ នោះគឺថា "វាជាការចាំបាច់ដែលបង្ហាញថា ប្រទេសភាគច្រើន ប្រសិនបើមិនបានប្រទេសទាំងអស់ ត្រូវអនុម័តសញ្ញាណដូចគ្នា" ហើយថា "ក្នុងករណីណាក៏ដោយ ប្រព័ន្ធច្បាប់សំខាន់ៗ នៅលើពិភពលោកសម្រេចយកវិធីសាស្ត្រដូចគ្នាចំពោះសញ្ញាណនេះ"[44]។ ទោះជាយ៉ាងណាក៏ដោយ ដោយសារក្នុងការអនុវត្ត តុលាការស្ទើរតែមិនអាចពិនិត្យទៅលើច្បាប់ក្នុងស្រុករបស់បណ្តារដ្ឋទាំងអស់នៅទូទាំងពិភពលោកបាន តុលាការគួរតែត្រូវបានអនុញ្ញាតឱ្យផ្តោតការពិនិត្យទៅលើរដ្ឋតំណាងដែលបានជ្រើសរើសទៅបានហើយ។ *វិធីសាស្ត្រ*នៃការពិនិត្យបែបជ្រើសរើសនេះនឹងមិនត្រូវឱ្យប៉ះពាល់ដល់*បទដ្ឋាន* "ប្រទេសភាគច្រើន ប្រសិនបើមិនបានទាំងអស់" ទេ។ ស្របពេលជាមួយគ្នានោះ ប្រសិនបើការពិនិត្យបែបជ្រើសរើសនេះបានបង្ហាញថា ពុំមានឯកភាពដូចដែលបានតម្រូវទេ គេអាចសន្និដ្ឋានយ៉ាងច្បាស់ថា ពុំមានគោលការណ៍ទូទៅក្នុងចំណោមបណ្តារដ្ឋនានានៅទូទាំងពិភពលោកទេ។

23. ភាពទុកចិត្តបាននៃការពិនិត្យបែបជ្រើសរើស ពឹងផ្អែកយ៉ាងទូលំទូលាយទៅលើភាពជាតំណាងនៃកម្មវត្ថុដែលបានជ្រើសរើស ដែលមានលក្ខណៈខុសៗគ្នា និងត្រូវបានកំណត់ដោយគោលបំណងនៃ

---

[43] *រឿងក្តីដែលពាក់ព័ន្ធនឹងក្រុមហ៊ុន* Barcelona Traction, Light and Power Company, Ltd. *(ប្រទេសប៊ែលហ្ស៊ិក តទល់នឹង ប្រទេសអេស្ប៉ាញ)* "សាលក្រម" [ឆ្នាំ ១៩៧០] របាយការណ៍របស់តុលាការ ICJ ៣ កថាខណ្ឌ ៥០ (ភាសាអង់គ្លេស)។

[44] សាលដីកាបណ្តឹងសាទុក្ខលើ*រឿងក្តី* Tadić កថាខណ្ឌ ២២៥ (ភាសាអង់គ្លេស)។ ឯកសារលេខ **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧។

ការពិនិត្យនីមួយៗ។ ដោយសារ គោលបំណងនៅទីនេះ គឺដើម្បីកំណត់អត្តសញ្ញាណគោលការណ៍ទូទៅមួយ ជាគោលការណ៍ដែលត្រូវបានចែករំលែកដោយបណ្តារដ្ឋទាំងអស់នៅទូទាំងពិភពលោក រដ្ឋទាំងអស់ត្រូវតែមានតំណាងនៅក្នុងការពិនិត្យក្នុងករណីនេះ ពុំមានបញ្ហាពាក់ព័ន្ធនឹងនិយមន័យ *ជាធម្មតា*ពីបណ្តារដ្ឋ "ដែលត្រូវបានប៉ះពាល់ជាពិសេស" ទេ[45] នៅពេលនិយាយដល់គោលការណ៍ទូទៅ។ ទោះជាយ៉ាងណា មាត្រា ២១(១)(គ) នៃលក្ខន្តិកៈទីក្រុងរ៉ូម លើកឡើងថា ក្នុងការកំណត់អត្តសញ្ញាណគោលការណ៍ទូទៅរបស់ច្បាប់ព្រហ្មទណ្ឌរបស់បណ្តាប្រជាជាតិ នៅទូទាំងពិភពលោក "ច្បាប់ជាតិរបស់បណ្តារដ្ឋដែលនឹងអនុវត្តជាធម្មតានូវយុត្តាធិការទៅលើបទល្មើស" ត្រូវតែបានបញ្ចូលជាពិសេសទៅក្នុងការពិនិត្យបែបជ្រើសរើសមួយ។ បណ្តារដ្ឋទាំងនោះរួមមាន "រដ្ឋដែលបទល្មើសត្រូវបានប្រព្រឹត្ត (ជាសំខាន់) នៅលើទឹកដីរបស់ខ្លួន ដែលជនជាប់ចោទមានសញ្ជាតិរបស់រដ្ឋនោះ ឬដែលជនជាប់ចោទត្រូវបានដាក់ពន្ធនាគារនៅក្នុងរដ្ឋនោះ"[46]។ ទោះបី វាទំនងជាមិនស៊ីសង្វាក់គ្នាទៅនឹងចរិត "ទូទៅ" នៃ "គោលការណ៍ទូទៅ" ក៏ដោយ ក៏ចំណាប់អារម្មណ៍ពិសេសចំពោះ "បណ្តារដ្ឋដែលនឹងអនុវត្តជាធម្មតានូវយុត្តាធិការទៅលើបទល្មើស" នេះ ត្រូវបានបណ្តារដ្ឋមួយចំនួនយល់ថា បានធ្វើយុត្តិកម្មដោយគោលការណ៍នីត្យានុកូលភាពរួចហើយ"[47]។ ស្រដៀងគ្នានេះដែរ អង្គបុរេជំនុំជម្រះបានច្រានចោលទឡ្ហីករណ៍របស់សហព្រះរាជអាជ្ញាដែលបានលើកឡើងពីភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នៅ អ.វ.ត.ក ដោយមិនទាំងបានពិចារណាថាតើមាន ឬមិនមាន គោលការណ៍រួមនៅក្នុងច្បាប់ក្នុងស្រុក ដោយផ្អែកលើមូលដ្ឋានថា នៅក្នុងកាលៈទេសៈណាក៏ដោយ ក៏ជនជាប់ចោទមិនអាចព្យាករណ៍បានចំពោះទស្សនៈទេ នៅក្នុងពេលវេលាដែលពាក់ព័ន្ធ ដោយសារពុំមាន "ការគាំទ្រ" ណាមួយ ចំពោះទស្សនៈបែបនេះ នៅក្នុងច្បាប់កម្ពុជាបច្ចុប្បន្ន ហើយថា ហេតុនេះវាផ្ទុយទៅនឹងគោលការណ៍នីត្យានុកូលភាពដែលអនុវត្តចំពោះ

---

45 *រឿងក្តី* *North Sea Continental Shelf Cases* "សាលក្រម" [ឆ្នាំ ១៩៦៩] របាយការណ៍របស់តុលាការ ICJ ៣ កថាខណ្ឌ ៧៣ (ភាសាអង់គ្លេស) ទម្លាប់អនុវត្ត និងឥរិយាបថរបស់បណ្តារដ្ឋ "ដែលរងការប៉ះពាល់" ត្រូវបានតុលាការ ICJ ចាត់ទុកថាជា*ការចាំបាច់* (ដែលក្នុងការស្ទាបស្ទង់មតិត្រូវតែបញ្ចូលបណ្តារដ្ឋទាំងនេះ) តែកត្តានានា*មិនពេញលេញ*ក្នុងការសម្រេចពីច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

46 Antonio Cassese និងអ្នកផ្សេងទៀត *លក្ខន្តិកៈទីក្រុងរ៉ូម នៃតុលាការព្រហ្មទណ្ឌអន្តរជាតិ៖ សេចក្តីអធិប្បាយ ក្បាលទី ២ (The Rome Statute of the International Criminal Court: A Commentary: Volume II)* (ឆ្នាំ ២០០២) ("Cassese *សេចក្តីអធិប្បាយពីលក្ខន្តិកៈទីក្រុងរ៉ូម*") ទំព័រ ១០៧៥ (ភាសាអង់គ្លេស)។

47 Cassese *សេចក្តីអធិប្បាយពីលក្ខន្តិកៈទីក្រុងរ៉ូម* ទំព័រ ១០៧៥ (ភាសាអង់គ្លេស)។

ទស្សនៈនេះ"[48]។ សរុបមក មេធាវីការពារក្តីរក្សាជំហរថា ការបង្ហាញគោលការណ៍ទូទៅតម្រូវថា បណ្តារដ្ឋ "ភាគច្រើន ប្រសិនបើមិនបានទាំងអស់" ត្រូវចែករំលែកនូវសញ្ញាណដូចគ្នា ហើយបណ្តារដ្ឋដែលត្រូវបានជ្រើសរើសយកមកពិនិត្យ ត្រូវតែតំណាងឲ្យបណ្តាប្រជាជាតិទាំងអស់នៅលើពិភពលោក ទោះបីជាត្រូវចាប់អារម្មណ៍ជាពិសេសទៅលើច្បាប់របស់បណ្តារដ្ឋដែលនឹងអនុវត្តយុត្តាធិការជាធម្មតាទៅលើបទល្មើសនោះក៏ដោយ។

## ឃ. ច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនគាំទ្រដល់អត្ថិភាពរបស់សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នៅក្នុងពេលវេលាដែលពាក់ព័ន្ធទេ

24. ដោយផ្អែកលើទឡ្ហីករណ៍នានាដែលបានលើកឡើងខាងលើ ច្បាស់ណាស់ដែលថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពឹងផ្អែកទៅលើមូលដ្ឋានដែលមានវិការៈជាសារវ័ន្ត។ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងនៅ អ.វ.ត.ក *មិនមាន* កំហុសលើអង្គច្បាប់ទេ នៅពេលដែលអង្គជំនុំជម្រះទាំងពីរនេះជ្រើសរើសមិនចាត់ទុកច្បាប់ក្នុងស្រុកជាភស្តុតាងនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិ តែផ្ទុយទៅវិញបានកំហិតការពិនិត្យរបស់ខ្លួនទៅលើលិខិតុបករណ៍ និងរឿងក្តីអន្តរជាតិ ដែលត្រូវបានជំនុំជម្រះនៅតុលាការអន្តរជាតិ ឬតុលាការជាតិដែលអនុវត្តច្បាប់អន្តរជាតិ។ ដោយសារវិធីសាស្ត្ររបស់អង្គជំនុំជម្រះទាំងពីរនេះចំពោះច្បាប់ទំនៀមទម្លាប់អន្តរជាតិមិនមានវិការៈ ពុំមានហេតុផលអ្វីដែលត្រូវទៅរំខានដល់សេចក្តីសម្រេចពីមុនៗទេ (យ៉ាងហោចណាស់ពាក់ព័ន្ធនឹងបញ្ហានេះ)។ ទោះជាយ៉ាងនេះក្តី មេធាវីការពារនឹងឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋាននានាដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា ពាក់ព័ន្ធនឹងករណី "ថ្មីៗ" ដែលអង្គជំនុំជម្រះទាំងពីរមិនទាន់បានយកទៅពិចារណា នៅក្នុងការវិនិច្ឆ័យពីមុនៗរបស់ខ្លួនចំពោះភាពអាចអនុវត្តបាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣។

### *(i) ការវិភាគទាំងលើរឿងក្តីនានាដែលសហព្រះរាជអាជ្ញាបានយកមកសំអាង*

25. ដើម្បីគាំទ្រដល់ទឡ្ហីករណ៍របស់ខ្លួនដែលថា សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ធ្លាប់មាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនោះ សហព្រះរាជអាជ្ញាបានយោងទៅដល់រឿងក្តីចំនួនដប់ពាក់ព័ន្ធនឹងសង្គ្រាមលោកលើកទី២ ដែលត្រូវបានជំនុំជម្រះដោយតុលាការយោធាអន្តរជាតិ ("IMT") ឬ

---

[48] ឯកសារលេខ **D97/15/9** សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៨៧។

ដោយតុលាការជាតិផ្សេងៗទៀត អនុលោមទៅតាម ច្បាប់លេខ ១០ របស់ក្រុមប្រឹក្សាគ្រប់គ្រង ("CCL")។ រឿងក្តីចំនួនពីរ ក្នុងចំណោមរឿងក្តីទាំងដប់ មានឈ្មោះថា *រឿងក្តី Borkum Island* និង *រឿងក្តី Essen Lynching*[49] ត្រូវបានអង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY ក្នុង *រឿងក្តី Tadić* យកមកសំអាងជាភស្តុតាងនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣។ អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានពិនិត្យយ៉ាងប្រុងប្រយ័ត្នរួចទៅហើយទៅលើរឿងក្តីទាំងពីរនេះ និងបានសន្និដ្ឋានថា មូលដ្ឋាននៃការផ្តន្ទាទោសនៅក្នុងរឿងក្តីទាំងនេះ "មិនអាចបញ្ជាក់ឲ្យបានប្រាកដប្រជាទេ ដោយសារ គ្មានសាលក្រមដែលមានសំអាងហេតុច្បាស់លាស់" ត្រូវបានផ្សព្វផ្សាយ ហើយថាផ្អែកលើកំណត់ត្រាដែលនៅសល់ "សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ មិនមែនជាការសំអាងដែលអាចមានតែមួយគត់នោះទេ" ដោយសារមូលដ្ឋាននៃការផ្តន្ទាទោសទាំងនោះ "អាចជាទម្រង់នៃការទទួលខុសត្រូវផ្សេងទៀតដែលស្មើគ្នា"[50]។ ហេតុនេះ មេធាវីការពារក្តីយល់ថា ពុំចាំបាច់ឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋាននានារបស់សហព្រះរាជអាជ្ញាចំពោះរឿងក្តីទាំងពីរនេះទេ។ សារណាតបនានាទៅនឹងរឿងក្តីផ្សេងៗទៀតរបស់សហព្រះរាជអាជ្ញាមានដូចខាងក្រោម។

26. ***រឿងក្តី Sauckel៖*** ពាក់ព័ន្ធនឹងការផ្តន្ទាទោសលើ Fritz Sauckel របស់តុលាការយោធាអន្តរជាតិ សហព្រះរាជអាជ្ញាអះអាងថា Sauckel ត្រូវបានផ្តន្ទាទោសពីបទឧក្រិដ្ឋកម្មសង្គ្រាម និង ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ចំពោះការប្រព្រឹត្តិបែបអមនុស្សធម៌ទៅលើពលករជាជនបរទេស ទោះបីគាត់មិនមានចេតនាឲ្យមានអំពើព្រៃផ្សៃនោះក៏ដោយ[51]។ ទោះជាយ៉ាងណា ជាថ្មីម្តងទៀត ផ្ទុយពីអំណះអំណាងរបស់សហព្រះរាជអាជ្ញា តុលាការយោធាអន្តរជាតិមិនបានសន្និដ្ឋានថា Sauckel គ្មានចេតនាទេ។ កាន់តែផ្ទុយស្រឡះនោះគឺថា៖ តុលាការយោធាអន្តរជាតិបានសម្រេចថា ទោះបីការណ៍ដែលថា Sauckel មិនបង្ហាញថាបាន "គាំទ្រឲ្យមានអំពើព្រៃផ្សៃ" ក៏ដោយ ក៏ Sauckel ពិតជាបង្ហាញជំហររបស់ខ្លួនចំពោះការប្រព្រឹត្តិទៅលើពលករថា ខ្លួនបាន "កេងប្រវ័ញ្ចពីពួកគេ

---

49 ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១ ដល់ ៣៣។

50 ឯកសារលេខ **E100/6** សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣០ ដល់ ៣១។ ឯកសារលេខ **D97/15/9** សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះលើឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៧៩ ដល់ ៨១។

51 ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៨ ដល់ ២៩។

នៅក្នុងកម្រិតខ្ពស់បំផុត ដើម្បីឲ្យការចំណាយកាន់តែតិចបំផុត”[52]។ ជាងនេះទៀត សាលក្រមបាន សន្និដ្ឋានយ៉ាងច្បាស់ថា “[Sauckel] បានដឹងពីវិធីសាស្ត្រគ្មានក្តីមេត្តាដែលត្រូវបានអនុវត្តដើម្បី ទទួលបានពលករ និងបានគាំទ្រដល់វិធីសាស្ត្រទាំងនោះយ៉ាងមុតមាំ ដោយផ្អែកលើមូលដ្ឋានថា វិធីសាស្ត្រទាំងនេះត្រូវអនុវត្តចាំបាច់ដើម្បីបំពេញកូតា”[53]។ ហេតុនេះ វាច្បាស់ណាស់ថា តុលាការ យោធាអន្តរជាតិពិតជាបានសន្និដ្ឋានថា Sauckel មានចេតនា។ ទោះបី គាត់មាន ឬមិនមានចេតនា ក្នុងការធ្វើបាបសម្រាប់តែអំពើព្រៃផ្សៃតែមួយ ឬគ្រាន់តែបំពេញកូតា ឬកេងប្រវ័ញ្ចពីពួកគេនៅក្នុង កម្រិតមួយខ្ពស់បំផុត តាមតែអាចធ្វើទៅបានក៏ដោយ ក៏តុលាការយោធាអន្តរជាតិពឹងផ្អែកតែលើ *សំអាងហេតុ*មួយ ដោយពុំមានបង្ហាញពី*ចេតនា*ទេ។ ហេតុនេះ រឿងក្តីមិនគាំទ្រដល់សហ ឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ដែលកំណត់ឲ្យបុគ្គលត្រូវទទួលខុសត្រូវចំពោះបទល្មើសនានាដែលពួកគេ ពុំមានចេតនា និងដែលត្រូវបានប្រព្រឹត្តដោយអ្នកផ្សេងទៀតនោះទេ។ ទោះបី តុលាការយោធា អន្តរជាតិមិនបានសន្និដ្ឋានថា Sauckel មានចេតនាក៏ដោយ ក៏តុលាការមានសមហេតុផលជាង ដែលថា គាត់ត្រូវបានផ្តន្ទាទោសទៅតាមទម្រង់នៃការទទួលខុសត្រូវរបស់ថ្នាក់លើ មិនមែនទៅតាម សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ទេ ដោយសារថា តុលាការយោធាអន្តរជាតិបានសន្និដ្ឋានថា “Sauckel មានការទទួលខុសត្រូវខ្ពស់ជាងគេចំពោះកម្មវិធីពលកររបៀបទាសករ” ហើយ “នៅ ពេលដែលមានព្រឹត្តិការណ៍ដែលបានលើកឡើងទាំងនោះ គាត់មិនបានប្រើអំណាចត្រួតត្រាទៅនឹងទី កន្លែងទាំងនេះ”ឡើយ[54]។

27. ***រឿងក្តី Speer*** ៖ ចំពោះការផ្តន្ទាទោសរបស់តុលាការយោធាអន្តរជាតិទៅលើ Albert Speer សហ ព្រះរាជអាជ្ញាអះអាងថា Speer ត្រូវបានផ្តន្ទាទោសពី “បទបំពារបំពានទៅលើកម្មករ” ដែលគាត់ពុំ មានចេតនា ដោយសារថា គាត់គ្រាន់តែបានដឹងថាមានកម្មវិធីពលករបែបទាសករ[55]។ ទោះជា យ៉ាងណា ការពិត សាលក្រមមិនបានថ្លែងថា Speer ត្រូវបានផ្តន្ទាទោសពីបទ “បំពារបំពាន” ទេ។ ផ្ទុយទៅវិញ សាលក្រមផ្តោតទៅលើ “អំណាចទូលំទូលាយរបស់ Speer ទៅលើផលិតកម្ម” និង

---

[52] “ការជំនុំជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមសំខាន់ៗនៅចំពោះមុខតុលាការយោធាអន្តរជាតិ” Nuremberg ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ១៩៤៥ ដល់ ថ្ងៃទី ១ ខែ តុលា ឆ្នាំ ១៩៤៦ Vol. XXII (“សាលក្រមរបស់តុលាការយោធាអន្តរជាតិ”) ទំព័រ ៥៦៨ (ភាសា អង់គ្លេស)។

[53] សាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ៥៦៧ (ភាសាអង់គ្លេស)។

[54] សាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ៥៦៧ (ភាសាអង់គ្លេស)។

[55] ឯកសារលេខ **F11** បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣០។

"អំណាចណែនាំឱ្យ Sauckel ផ្តល់ពលករ"[56] ការដឹងច្បាស់របស់ Speer (ផ្ទុយពីការតែត្រឹមតែព្យាករណ៍បានចំពោះផលវិបាកដែលទំនងជាកើតមាន) ថា ពលករដែលគាត់ទាមទារពី Sauckel ត្រូវបានផ្គត់ផ្គង់ដោយពលករបរទេស "ក្នុងការបម្រើការងារដោយការបង្ខិតបង្ខំ"[57] និងការប្រជុំជាច្រើនដងដែល Speer បានទៅចូលរួម ដោយនៅក្នុងកិច្ចប្រជុំទាំងនោះ "មានការយល់ស្របថា Sauckel គួរតែនាំយកពលករដោយប្រើកម្លាំងពីបណ្តាដែនដីដែលស្ថិតក្រោមការកាន់កាប់"[58]។ ហេតុនេះ អំណានដែលមានភាពសមហេតុសមផលជាងចំពោះការផ្តន្ទាទោសរបស់តុលាការយោធាអន្តរជាតិទៅលើ Speer គឺថា គាត់ត្រូវបានផ្តន្ទាទោសពីបទចូលរួមដោយចេតនាទៅក្នុងបញ្ហា "ពលករបែបទាសករ" (ធម្មនុញ្ញទីក្រុងឡុងដ៍ មាត្រា ៦(ខ) បទឧក្រិដ្ឋសង្គ្រាម) ឬ "ការធ្វើឱ្យទៅជាទាសករ" (ធម្មនុញ្ញទីក្រុងឡុងដ៍ មាត្រា ៦(គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ) ជាជាង "ការធ្វើបាប" ដែលជាលទ្ធផល ដោយគ្មានចេតនា តែអាចប្រមើលមើលជាមុនបាន (ធម្មនុញ្ញទីក្រុងឡុងដ៍ មាត្រា ៦(ខ) បទឧក្រិដ្ឋសង្គ្រាម) ឬ "អំពើអមនុស្សធម៌ផ្សេងៗទៀត" (ធម្មនុញ្ញទីក្រុងឡុងដ៍ មាត្រា ៦(គ) ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ)។ ហេតុនេះ រឿងក្តីនេះមិនគាំទ្រដល់ការអនុវត្តសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ ទេ។

28. ***រឿងក្តី Hans Renoth និងជនជាប់ចោទបីនាក់ផ្សេងទៀត*** ទាក់ទងនឹងរឿងក្តី *Hans Renoth និងជនជាប់ចោទបីនាក់ផ្សេងទៀត* សហព្រះរាជអាជ្ញាចោទប្រកាន់ថា ជនជាប់ចោទបីនាក់ផ្សេងទៀតត្រូវបាន "ផ្តន្ទាទោសពីបទមនុស្សឃាតដោយផ្អែកលើអង្គហេតុដែលថា ពួកគេអាចប្រមើលមើលបានថា ការវាយដំនេះនឹងឈានទៅដល់ការសម្លាប់" ទោះបីជា "មិនមានជនជាប់ចោទណាម្នាក់ ក្រៅពី Renoth បានប្រើប្រាស់កម្លាំងដែលអាចបណ្តាលឱ្យស្លាប់ ឬមានចេតនាសម្លាប់ក៏ដោយ"[59]។ ការអះអាងនេះគ្មានមូលដ្ឋានឡើយ។ នៅក្នុងរឿងក្តីនោះ រឿងក្តីរបស់អយ្យការគឺថា ជនជាប់ចោទទាំងអស់បួននាក់មានគម្រោងរួម "ក្នុងការប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម" ហើយជនជាប់ចោទបីនាក់ផ្សេងទៀតបានចូលរួមនៅក្នុងការវាយដំ ចំណែក Renoth បានបាញ់អ្នកបើក

[56] សាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ៥៧៧ (ភាសាអង់គ្លេស)។

[57] សាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ៥៧៨ (ភាសាអង់គ្លេស)។

[58] សាលក្រមរបស់តុលាការយោធាអន្តរជាតិ ទំព័រ ៥៧៨ (ភាសាអង់គ្លេស)។

[59] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៤។

យន្តហោះសម្លាប់ចោលជាចុងក្រោយ[60]។ ករណីថាតើគម្រោងរួមរបស់ពួកគេគឺដើម្បីប្រព្រឹត្តឧក្រិដ្ឋកម្មសង្គ្រាម ពោលគឺ *ការកាប់សម្លាប់* ឬ អំពើផ្សេង ឬឧក្រិដ្ឋកម្មសង្គ្រាមទូទៅ ឬយ៉ាងណានោះ គឺពុំមានលក្ខណៈច្បាស់លាស់។ វាអាចទំនងណាស់ថា ជនជាប់ចោទទាំងបួននាក់ត្រូវបានចោទប្រកាន់ និងសម្រេចឲ្យមានពិរុទ្ធភាពដោយសារមានចេតនារួមក្នុងការកាប់សម្លាប់។ អ្វីដែលគួរឲ្យចាប់អារម្មណ៍ជាងនេះ នៅពេលឆ្លើយតបទៅនឹងរឿងក្តីរបស់មេធាវីការពារក្តីថា ជនជាប់ចោទទាំងបីនាក់ផ្សេងទៀតពុំបានចូលរួមនៅក្នុងការវាយដំ ប៉ុន្តែ គ្រាន់តែបានឈរមើលនៅក្បែរនោះប៉ុណ្ណោះ អយ្យការនៅក្នុងរឿងក្តីនោះបានអះអាងថា ការត្រឹមតែមានវត្តមានអាចត្រូវបានមើលឃើញថាជា "ការជួយ និងជំរុញ"[61]។ ហេតុដូច្នេះ ជាថ្មីម្តងទៀត រឿងក្តីនេះពុំគាំទ្រលើការអនុវត្តសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នោះទេ។

29. ***រឿងក្តី Pohl*:** ពាក់ព័ន្ធនឹងរឿងក្តី *Pohl* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាត្រូវបានផ្តោតលើចុងចោទចំនួនពីរនាក់គឺ Hans Hohberg និង Hans Baier។ ចំពោះ Hohberg សហព្រះរាជអាជ្ញាអះអាងថា Hohberg ដែលពុំមែនជាសមាជិកនៃ SS នោះ "ពុំបានចូលរួមដោយសកម្មក្នុងឧក្រិដ្ឋកម្ម" ប៉ុន្តែនៅតែត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពលើ "អំពើហួសហេតុ" នៅក្នុងជំរំប្រមូលផ្តុំដោយសារគាត់ធ្លាប់បានទៅពិនិត្យជំរំទាំងនោះ ហើយពុំអាចថាពុំបានដឹងនូវអ្វីដែលបានកើតឡើងនៅទីនោះទេ ហើយ "SS ទាំងនោះគឺជាផលវិបាកដែលអាចប្រមើលមើលបាននៃផែនការរួម"[62]។ ទោះបីជាយ៉ាងនេះក្តី ជាថ្មីម្តងទៀត សាលក្រមពិតជាពុំបានបញ្ជាក់ថាតើឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិជាក់លាក់ណាមួយដែលត្រូវបានសម្រេចថា Hohberg មានពិរុទ្ធភាពនោះ។ គេអាចដែលថា Hohberg ពិតជាត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពពីបទចូលរួមដោយចេតនានៅក្នុង "ពលកម្មទាសករ" (ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មាត្រា II(១)(ខ) ឧក្រិដ្ឋកម្មសង្គ្រាម) និង "ការធ្វើឲ្យទៅជាទាសករ" (ច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០ មាត្រា II(១)(គ) ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ពុំមែន "ការធ្វើបាប" ឬ "អំពើអមនុស្សធម៌" ដែលគាត់ពុំមានចេតនាតាមរយៈសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នោះឡើយ។

---

[60] ការជំនុំជម្រះ *Hans Renoth និងជនជាប់ចោទបីនាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេស ថ្ងៃទី ៨ ដល់ ថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៤៦ UNWCC 'Law Reports of the Trials of War Criminals' ("របាយការណ៍ច្បាប់របស់ UNWCC") វ៉ុល XI ទំព័រ ៧៦។

[61] របាយការណ៍ច្បាប់របស់ UNWCC វ៉ុល XI ទំព័រ ៧៧។

[62] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៥។

ជាការពិតណាស់ ការចូលរួមដោយចេតនានៅក្នុង "ពលកម្មទាសករ" និង "ការធ្វើឱ្យទៅជាទាសករ" ទំនងជាការសន្និដ្ឋានសមហេតុផលជាងដោយហេតុថា សាលក្រមបានផ្តោតលើករណីដែលថា Hohberg គឺជា "អ្នកចូលរួមយ៉ាងសកម្មម្នាក់នៅក្នុងសហគ្រាសសេដ្ឋកិច្ចនៃ SS"[63] ព្រមទាំងបានរកឃើញថា "Hohberg គឺជាប់ទាក់ទងយ៉ាងជាក់លាក់ជាមួយនឹងជំរំប្រមូលផ្តុំ"[64] ហើយ "នៅពេល Hermann Goering Works ត្រូវការពលកម្មពីអ្នកជាប់ឃុំនៅទីនោះ Hohberg បានចូលរួមសន្និសីទដែលបានពិចារណាលើវិធី និងមធ្យោបាយក្នុងការផ្គត់ផ្គង់អ្នកជាប់ឃុំនៅទីនោះ"[65] ហើយគាត់បានដឹងអំពីប្រាក់ឈ្នួលប្រចាំថ្ងៃដែលបានទូទាត់ឱ្យទៅអ្នកជាប់នៅទីនោះ និងបានផ្តល់យោបល់របស់គាត់លើបញ្ហា ថាតើសហគ្រាសទាំងនោះគួរទូទាត់ប្រាក់ឈ្នួលចំនួនប៉ុន្មានឱ្យទៅ Reich[66]។

30. ស្រដៀងគ្នានេះដែរ សហព្រះរាជអាជ្ញាអះអាងថា Hans Baier ដែលជាចុងចោទម្នាក់ក្នុងចំណោមចុងចោទផ្សេងទៀតនៅក្នុងរឿងក្តីនោះ ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពតាមរយៈឧក្រិដ្ឋកម្មនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ដែល "ជាផលវិបាកដែលអាចប្រមើលមើលបានចំពោះពលកម្មទាសករ"[67]។ សាលក្រមពុំបានបញ្ជាក់ថា Baier ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពលើអំពើអ្វីដែលនៅក្រៅចេតនារបស់គាត់ ឬជាផលវិបាកចេញពីអំពើរបស់គាត់នោះទេ។ ផ្ទុយមកវិញ សាលក្រមបានសម្រេចយ៉ាងច្បាស់លាស់ថា មូលដ្ឋានសម្រាប់ការសម្រេចឱ្យមានពិរុទ្ធភាពលើរូបគាត់គឺថា Baier "ក្នុងតួនាទីរបស់គាត់ជានាយសេនាធិការផ្នែក W បានចូលរួមយ៉ាងសកម្ម និងដោយមានការយល់ស្របជាមួយគ្នានៅក្នុងការកេងប្រវ័ញ្ចលើពលកម្មទាសករ" ហើយ "ក្នុងនាមជាសិទ្ធិវន្តនៃ Hohberg, Baier បានជាប់ពាក់ព័ន្ធច្រើនដូច Hohberg ដែរនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិដែលកើតចេញពីសកម្មភាពរបស់គាត់ក្នុងនាមជានាយសេនាធិការផ្នែក W នោះ"[68]។ ជាពិសេស សាលក្រមបានរកឃើញថា Baier បានត្រួតពិនិត្យលើការគ្រប់គ្រងសហគ្រាសដែល

---

[63] រឿងក្តី *The Pohl* 'Trials of War Criminals before the Nuremberg Military Tribunals under Control Council Law No. 10' ("ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក") វ៉ុល V ទំព័រ ១០៤២។

[64] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១០៤០។

[65] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១០៤២។

[66] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១០៤១។

[67] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៦។

[68] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១០៤៣ ទំព័រ ១០៤៧។

បានប្រើប្រាស់កម្លាំងពលកម្មរបស់អ្នកទោស បានត្រួតពិនិត្យ និងកំណត់ប្រាក់ឈ្នួល និងម៉ោងការងារដើម្បីកេងប្រវ័ញ្ចអ្នកជាប់ឃុំ និងបានចុះហត្ថលេខាលើឯកសារផ្លាស់ប្តូរជំរំពលកម្មដោយបង្ខំទៅជាជំរំប្រមូលផ្តុំ[69]។ ហេតុដូច្នេះ រឿងក្តីនេះពុំបានផ្តល់ជាមូលដ្ឋានចំពោះការជំទាស់ថាការសម្រេចឱ្យ Baier មានពិរុទ្ធភាពគាំទ្រលើសហកម្មឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ នោះឡើយ។

31. ***រឿងក្តី RuSHA*៖** ពាក់ព័ន្ធនឹងរឿងក្តី *RuSHA* សហព្រះរាជអាជ្ញាចោទប្រកាន់ថា ការសម្រេចឱ្យ Hildebrandt មានពិរុទ្ធភាពគឺជាភស្តុតាងបង្ហាញអំពីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ពីព្រោះថាគាត់ត្រូវ "ទទួលខុសត្រូវចំពោះការព្យួរក" ដែលបានកើតចេញពីបញ្ជារបស់គាត់ឱ្យមាន "ការប្រព្រឹត្តិពិសេស" លើជនបរទេសដែលបានរួមភេទជាមួយនឹងស្ត្រីអាល្លឺម៉ង់ ដោយបានដឹងថា ការចងព្យួរកនឹងអាចបណ្តាលមកពី "ប្រព្រឹត្តិពិសេស"[70] នេះ។ ការអះអាងរបស់សហព្រះរាជអាជ្ញានៅក្នុងករណីនេះគឺមានកំហុសលើទិដ្ឋភាពមួយចំនួន។ ទិដ្ឋភាពទីមួយ ទោះបីជា សាលក្រមបានសម្រេចថា Hildebrandt ក្នុងនាមជាប្រធាន RuSHA "បានចូលរួមយ៉ាងសកម្មនៅក្នុង និងទទួលខុសត្រូវព្រហ្មទណ្ឌចំពោះ [...] ការដាក់ទណ្ឌកម្មខុសច្បាប់ និងមិនត្រឹមត្រូវលើជនជាតិបរទេសចំពោះការរួមភេទជាមួយនឹងជនជាតិអាល្លឺម៉ង់ក៏ដោយ[71] ក៏ យោងតាមអង្គហេតុ វាពុំច្បាស់លាស់ថាតើគាត់ត្រូវបានសម្រេចឱ្យទទួលខុសត្រូវជាក់លាក់លើការចងព្យួរក ឬក៏យ៉ាងណានោះទេ។ ទិដ្ឋភាពទីពីរ ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា វាពុំច្បាស់លាស់ទេថាតើសាលាក្តីពិតជាទទួលយកការអះអាងរបស់ Hildebrandt ថា គាត់បានដឹងត្រឹមតែលទ្ធភាពនៃការចងព្យួរកថាជាទម្រង់មួយនៃ "ប្រព្រឹត្តិពិសេសនេះ" តែប៉ុណ្ណោះ។ អ្វីដែលសាលាក្តីរកឃើញនោះគឺថា Hildebrandt ពិតជា "យល់លើពាក្យ "ប្រព្រឹត្តិពិសេសនេះ"[72] ហើយនៅក្នុងផ្នែកដំបូងៗនៅក្នុងសាលក្រម សាលាក្តីបានកត់សម្គាល់អំពីក្រឹត្យច្បាប់បានចេញដោយ RSHA ដែលបានបញ្ជាក់យ៉ាងច្បាស់ថា "ប្រព្រឹត្តិពិសេសគឺការចងព្យួរក"[73]។ RSHA និង RuSHA ដែលជា

---

[69] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១០៤៤-១០៤៥។

[70] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៧។

[71] រឿងក្តី *RuSHA* 'Trials of War Criminals before the Nuremberg Military Tribunals under Control Council Law No. 10' វ៉ុល V ទំព័រ ១៦១។

[72] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១២០។

[73] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១១៧។

ការិយាល័យនៃទីបញ្ជាការ SS[74] ត្រូវបានសាលាក្តីរកឃើញថាបានធ្វើការងាររួមគ្នានៅក្នុងការដាក់ទណ្ឌកម្មលើជនបរទេសដោយសារបានរួមភេទជាមួយនឹងស្ត្រីអាល្លឺម៉ង់[75]។ សាលាក្តីនោះក៏បានរកឃើញផងដែរថា "ជាក់ស្តែង ក្រឹត្យច្បាប់ ឬលិខិតទាក់ទងគ្រប់ទាំងអស់ទាក់ទងនឹងបញ្ហានេះចេញមកពីក្នុងការិយាល័យនៃ RuSHA ឬ ត្រូវបានបញ្ជូនទៅការិយាល័យនោះ"[76]។ ទិដ្ឋភាពទីបី ទោះក្នុងករណីណាក៏ដោយ ទោះបីជា Hildebrandt ពិតជាត្រូវបានរកឃើញថាទទួលខុសត្រូវលើការចងព្យួរកដែលគាត់ពុំមានចេតនា ប៉ុន្តែអាចប្រមើលមើលឃើញក៏ដោយ ក៏មូលដ្ឋាននៃការសម្រេចឱ្យគាត់មានពិរុទ្ធភាពអាចទំនងជា*ការចេញបញ្ជា* ពុំមែនសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នោះទេ។

32. ***រឿងក្តី Einsatzgruppen៖*** ពាក់ព័ន្ធនឹងរឿងក្តី *Einsatzgruppen* សហព្រះរាជអាជ្ញាអះអាងថា ទោះបីជាបានរកឃើញថា Franz Six ពុំពាក់ព័ន្ធនៅក្នុងកម្មវិធីធ្វើមនុស្សឃាតក៏ដោយ ក៏សាលាក្តីនោះ "បានសម្រេចឱ្យគាត់មានពិរុទ្ធភាពលើឧក្រិដ្ឋកម្មទាំងអស់របស់អង្គការនោះ រួមទាំងការកាប់សម្លាប់មនុស្សផងដែរ" ដែលគាត់ត្រូវបានរកឃើញថាជាផ្នែកមួយនៅក្នុងអង្គការនោះ[77]។ ការអះអាងនេះមានកំហុស និងលើកឡើងខុសពីក្នុងសាលក្រម។ ជនជាប់ចោទប្រាំមួយនាក់ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពលើបទចោទទីបី ក្នុងនាមជាសមាជិកនៅក្នុងអង្គការឧក្រិដ្ឋ អនុលោមតាមមាត្រា II(១)(ឃ)នៃច្បាប់ក្រុមប្រឹក្សាត្រួតពិនិត្យលេខ ១០[78]។ ទោះបីជាយ៉ាងនេះក៏ដោយ វាពុំមានន័យថា គាត់ត្រូវបានសម្រេចឱ្យទទួលខុសត្រូវលើឧក្រិដ្ឋកម្មទាំងអស់នៅក្នុងអង្គការនោះឡើយ។ ជនជាប់ចោទប្រាំមួយនាក់ក៏ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពលើបទចោទទីមួយ (ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ) ដោយចោទប្រកាន់ចុងចោទទាំងអស់ពីបទ "មនុស្សឃាត អំពើឃោរឃៅ និងអំពើអមនុស្សធម៌ផ្សេងទៀត"[79] និងបទចោទទីពីរ (ឧក្រិដ្ឋកម្មសង្គ្រាម) ដោយចោទប្រកាន់ចុងចោទទាំងអស់ពីបទ "អំពើឃោរឃៅ និងបទល្មើសប្រឆាំងនឹងបុគ្គល និង

---

[74] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ៤៣។

[75] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១១៧-១១៨។

[76] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល V ទំព័រ ១១៨។

[77] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨។

[78] រឿងក្តី *Einsatzgruppen* 'Trials of War Criminals before the Nuremberg Military Tribunals under Control Council Law No. 10' វ៉ុល IV ទំព័រ ៥២៦។

[79] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល IV ទំព័រ ១៥-១៦។

ទ្រព្យសម្បត្តិ [...] រួមទាំង ប៉ុន្តែពុំកម្រិតត្រឹម អំពើមនុស្សឃាត និងការធ្វើបាបអ្នកទោសសង្គ្រាម និងប្រជាជនស៊ីវិលនោះឡើយ [...]"[80]។ សាលាក្តីនៅក្នុងករណីនេះពន្យល់យ៉ាងច្បាស់អំពីមូលដ្ឋានសម្រាប់សម្រេចឲ្យជនចាប់ចោទប្រាំមួយនាក់មានពិរុទ្ធភាពលើបទចោទទីមួយ និងបទចោទទីពីរ។ មូលដ្ឋាននោះគឺថាទោះបីជាពុំជឿជាក់លើតួនាទីសកម្មរបស់គាត់នៅក្នុង "កម្មវិធីធ្វើមនុស្សឃាត" ក៏ដោយ ក៏សាលាក្តីពិតជាបានរកឃើញ "ភស្តុតាង" បង្ហាញថា ជនជាប់ចោទប្រាំមួយនាក់ "បានបង្កើតជាផ្នែកមួយនៃអង្គការដែលបានជាប់ពាក់ព័ន្ធនៅក្នុងអំពើឃោរឃៅ បទល្មើសផ្សេងៗ និងអំពើអមនុស្សធម៌ប្រឆាំងនឹងជនស៊ីវិល"[81]។ ហេតុដូច្នេះ វាបង្ហាញច្បាស់ថា ជនជាប់ចោទចំនួនប្រាំមួយនាក់ត្រូវបានសម្រេចឲ្យមានពិរុទ្ធភាពពីបទអំពើឃោរឃៅ និងអំពើអមនុស្សធម៌ដែលក៏ត្រូវបានចោទប្រកាន់នៅក្រោមបទចោទទីមួយ និងបទចោទទីពីរផងដែរ ប៉ុន្តែពុំមែនបទធ្វើមនុស្សឃាតនោះឡើយ។ ចំណុចខាងលើបង្ហាញច្បាស់ថា រឿងក្តីនេះពុំបង្ហាញភស្តុតាងនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ទាល់តែសោះ។

33. ***រឿងក្តី Sch. និងអ្នកផ្សេងទៀត៖*** សហព្រះរាជអាជ្ញាអះអាងថា តុលាការកំពូលនៅក្នុងរឿងក្តី *Sch. និងអ្នកផ្សេងទៀត* បានបង្ហាញការសង្កេតដែលគាំទ្រលើទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ ពោលគឺ៖

> ប្រសិនបើតុលាការរកឃើញថា ជនជាប់ចោទបានដឹង ឬក៏សូម្បីតែអាចស្មានពីលទ្ធភាពដែលថាគាត់អាចទទួលខុសត្រូវចំពោះជោគវាសនាដ៏អាក្រក់របស់ N នៅពេលគាត់នាំ N ទៅទីនោះ គាត់ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចំពោះអ្វីគ្រប់យ៉ាងដែលបានកើតឡើងចំពោះ N។

ចំពោះសហព្រះរាជអាជ្ញា ករណីនេះគាំទ្រលើទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ពីព្រោះតុលាការនេះ "បានសម្រេចថា បើទោះបីជា *Sch* មិនមានចេតនាឲ្យមានឧក្រិដ្ឋកម្មក៏ដោយ ក៏គាត់ត្រូវទទួលខុសត្រូវ" ចំពោះវាដដែល[82]។ អំណានរបស់សហព្រះរាជអាជ្ញាលើជំហររបស់តុលាការចំពោះចេតនារបស់ជនជាប់ចោទគឺមានកំហុស។ តុលាការដែលមានសមាសភាពក្រុមប្រឹក្សាវិនិច្ឆ័យនៅក្នុងរឿងក្តី

---

[80] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល IV ទំព័រ ២១។

[81] ការជំនុំជម្រះរបស់សាលាក្តីយោធានូរ៉ឹមប៊ឺក វ៉ុល IV ទំព័រ ៥២៦។

[82] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៩។

នោះបានរកឃើញថា Sch. "មានចេតនា និងបានទទួលស្គាល់ថា ការធ្វើបាបនេះបានកើតឡើង"[83]។ តុលាការកំពូលក៏បានរកឃើញថា៖

> សេចក្តីប្រកាសរបស់ជនជាប់ចោទថា N ទំនងត្រូវបាន "សម្លាប់" ភ្លាមៗនៅកន្លែងនោះបង្ហាញហួសពីវិមតិសង្ស័យថា [Sch. បាន] ដឹងអំពីលក្ខណៈពិតប្រាកដនៃទង្វើរបស់ពួកគេ ហើយជនជាប់ចោទជាពិសេសបានដឹងថា គាត់ពុំមែនត្រឹមតែឃោរឃៅ និងប្រើហិង្សាចំពោះ N ប៉ុណ្ណោះទេ គាត់ក៏បានអនុញ្ញាតដោយចេតនាឲ្យ N រងនូវអំពើហិង្សាផ្សេងទៀត [...] ដែលគាត់បានដឹងទាំងស្រុងថា N នឹងរងនូវអំពើហិង្សាដែលពុំអាចប៉ាន់ស្មានបាន[84]។

ផ្អែកលើសំអាងហេតុអំពីសាវតារទាំងនេះ ការសង្កេតដែលបានដកស្រង់ដោយសហព្រះរាជអាជ្ញាពុំបញ្ជាក់អំពីភាពធ្វេសប្រហែសរបស់ Sch.។ ម្យ៉ាងវិញទៀត តុលាការដែលមានសមាសភាពក្រុមប្រឹក្សាវិនិច្ឆ័យ បានរកឃើញថា Sch. មានពិរុទ្ធភាព "មិនត្រឹមតែដោយសារខកខានមិនបានធ្វើសកម្មភាពនេះ/សមស្រប/ប៉ុណ្ណោះទេ ក៏ប៉ុន្តែដោយសារបានប្រព្រឹត្តអំពើទាំងនេះយ៉ាងសកម្មផងដែរ"[85]។ តុលាការកំពូលក៏បានរកឃើញផងដែរថា "បើទោះជាការចូលរួមយ៉ាងសកម្មនៅក្នុងឧក្រិដ្ឋកម្មនេះពុំបានបង្ហាញឲ្យឃើញក៏ដោយ" ក៏ Sch. នៅតែអាចសម្រេចឲ្យទទួលខុសត្រូវចំពោះអំពើអកម្មដដែល ពីព្រោះជនរងគ្រោះ "ស្ថិតនៅក្រោមអំណាចរបស់ [Sch.] ទាំងស្រុង និងយ៉ាងពិតប្រាកដ។ ដោយសារហេតុផលនេះហើយទើបជនជាប់ចោទមានកាតព្វកិច្ចតាមផ្លូវច្បាប់ត្រូវបញ្ឈប់ និងទប់ស្កាត់ការវាយប្រហារណាមួយលើបុគ្គល ដែលស្ថិតនៅក្រោមការការពាររបស់ខ្លួន"[86]។ ជាក់ស្តែង តុលាការពុំបានពិចារណាលើពិរុទ្ធភាពរបស់ Sch. ចំពោះអំពើដែលមិនមែនជាអំពើសកម្ម និងអំពើអកម្មរបស់គាត់នោះទេ។ យោងតាមហេតុផលខាងលើនេះ ទាំង*អំពើពិរុទ្ធ ឬចេតនាពិរុទ្ធ*នៃរឿងក្តីនេះពុំគាំទ្រលើសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នោះឡើយ។

34. ***រឿងក្តី Martin Gottfried Weiss*៖** ទាក់ទងនឹងរឿងក្តី *Martin Gottfried Weiss* (រឿងក្តីមួយក្នុងក្តីទាក់ទងនឹងជំរំប្រមូលផ្តុំនៅ Dachau) សហព្រះរាជអាជ្ញាគ្រាន់តែយោងលើសេចក្តី

[83] "សេចក្តីសម្រេចរបស់តុលាការកំពូលសម្រាប់តំបន់អង់គ្លេស" វ៉ុល II សាលក្រម ("សាលក្រម *Sch. និងជនជាប់ចោទផ្សេងទៀត*") កថាខណ្ឌ ៣.១ (សូមមើល ឯកសារលេខ F11.1.52 ERN 01041020)។

[84] សាលក្រម *Sch. និងជនជាប់ចោទផ្សេងទៀត* កថាខណ្ឌ ៣.១ (សូមមើល ឯកសារលេខ F11.1.52 ERN 01041021)។

[85] សាលក្រម *Sch. និងជនជាប់ចោទផ្សេងទៀត* កថាខណ្ឌ ៣.១ (សូមមើល ឯកសារលេខ F11.1.52 ERN 01041021)។

[86] សាលក្រម *Sch. និងជនជាប់ចោទផ្សេងទៀត* កថាខណ្ឌ ៣.១ (សូមមើល ឯកសារលេខ F11.1.52 ERN 01041021)។

ថ្លែងការណ៍របស់ចៅក្រម Advocate តែប៉ុណ្ណោះអំពី "ច្បាប់ស្តីពីការទទួលខុសត្រូវលើគម្រោងរួម" ដោយបានអះអាងថា ពាក្យពេចន៍របស់គាត់ "ស្មើរតែជាការប្រកាសបញ្ជាក់យ៉ាងពិតប្រាកដអំពីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣"[87]។ ដោយហេតុថា មតិយោបល់របស់ចៅក្រម Advocate ពុំមែនជាសាលក្រម និងមិនអាចចាត់ទុកជាយុត្តិសាស្ត្រនោះ មេធាវីការពារក្តីនឹងឆ្លើយតបទៅនឹងមតិយោបល់នេះនៅក្នុងផ្នែកមួយដោយឡែកខាងក្រោម។

35. ***រឿងក្តី Shoichi Ikeda៖*** ក្រៅពីរឿងក្តីពាក់ព័ន្ធនឹងសង្គ្រាមលោកលើកទីពីរចំនួនដប់រឿងក្តី សហព្រះរាជអាជ្ញាក៏យោងលើរឿងក្តីមួយមកពី *ការជំនុំជម្រះ Batavia* ក្រោយសង្គ្រាម ដែលជំនុំជម្រះដោយអាជ្ញាធរហូឡង់ដ៏នៅលើទឹកដីឥណ្ឌូណេស៊ី។ សហព្រះរាជអាជ្ញាអះអាងថា ការសម្រេចឱ្យ Shoichi Ikeda មានពិរុទ្ធភាពពីបទរំលោភសេពសន្ថវៈ និងពេស្យាកម្មដោយបង្ខំ ដែលស្ថិតនៅក្រៅផែនការដំបូងនៃការបង្កើតផ្ទះបន ប៉ុន្តែពុំអាចប្រមើលមើលឃើញអំពីផលវិបាកកើតចេញពីផែនការនេះ ផ្តល់នូវភស្តុតាងបង្ហាញអំពីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣[88]។ ទោះបីជាយ៉ាងនេះក្តី សាលក្រមនេះលើកឡើងផ្ទុយពីនេះយ៉ាងច្បាស់ក្រឡែត។ សាលក្រមនេះគូសបញ្ជាក់ម្តងហើយម្តងទៀតថា ជនជាប់ចោទក្នុងនាមជា "មន្ត្រីជាន់ខ្ពស់" ពុំបានចាត់វិធានការស៊ើបអង្កេតឱ្យបានគ្រប់គ្រាន់ ក្រោយពេលគាត់បានរកឃើញភាពមិនប្រក្រតីនៅក្នុងឯកសាររដ្ឋបាលទាក់ទងនឹងផ្ទះបន[89]។ ចុងក្រោយ សាលក្រមបានសម្រេចថា "ប្រសិនបើជនជាប់ចោទបានវាយតម្លៃ និងអនុវត្តភារកិច្ចដែលគាត់ទទួលខុសត្រូវក្នុងនាមជាមន្ត្រី *heitan* ឱ្យបានត្រឹមត្រូវនោះ វាមិនយល់សោះថាតើហេតុអ្វីគាត់ពុំចាប់ផ្តើមស៊ើបអង្កេតភ្លាមៗលើស្ថានភាព និងហេតុការណ៍ពិតនោះទៅ" ហើយថា ជនជាប់ចោទត្រូវបានរកឃើញថាមានពិរុទ្ធភាព[90]។ ហេតុដូច្នេះ វាបង្ហាញឱ្យឃើញថា Shoichi Ikeda ត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពដោយផ្អែកលើការទទួលខុសត្រូវថ្នាក់លើ ពុំមែនសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នោះទេ។

36. ***មតិយោបល់ទូទៅ៖*** ក្រៅពីការវិភាគខាងលើ មេធាវីការពារក្តីចង្អុលបញ្ជាក់ថា គ្មានរឿងក្តីណាមួយ

[87] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០។

[88] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤១។

[89] រឿងក្តី *Queen ទល់នឹង Shoichi Ikeda* សាលក្រមលេខ 72A/1947 ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ១៩៤៨ ("រឿងក្តី *Queen ទល់នឹង Shoichi Ikeda*") ទំព័រ ៨, ៩ (សូមមើល ឯកសារ F11.1.59)។

[90] រឿងក្តី *Queen ទល់នឹង Shoichi Ikeda*") ទំព័រ ៩-១០ (សូមមើល ឯកសារ F11.1.59)។

បញ្ជាក់ច្បាស់ថា ជនជាប់ចោទត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពក្នុងនាមជា*អតិចារី* ក្រៅតែពីថាជា*ចារីបន្ទាប់បន្សំ*។ ទោះបីជាយ៉ាងនេះក៏ដោយ ដូចបានពិភាក្សាខាងលើ[91] ហេតុផលដែលថាអង្គជំនុំជម្រះតុលាការកំពូលរបស់តុលាការ ICTY នៅក្នុងរឿងក្តី *Tadić* បានបង្ហាញនូវទស្សនទាននៃសហឧក្រិដ្ឋកម្មរួមដែលថា វាសមហេតុផលដែលអាចសម្រេចឱ្យបុគ្គលទាំងឡាយទទួលខុសត្រូវក្នុងនាមជាអតិចារី ជាជាងត្រឹមតែជាអ្នកជួយ ឬជំរុញ[92]។ ហេតុដូច្នេះ ដើម្បីគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម វាត្រូវបង្ហាញឱ្យច្បាស់លាស់ថា ជនជាប់ចោទនៅក្នុងរឿងក្តីទាំងនោះមិនត្រឹមតែត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពប៉ុណ្ណោះនោះទេ ជនជាប់ចោទទាំងនេះថែមទាំងត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពក្នុងនាមជាអតិចារី ពុំមែនជាចារីបន្ទាប់បន្សំនោះឡើយ។ ករណីនេះក៏ហាក់ដូចជាវិធីសាស្ត្រដែលបានអនុវត្តដោយអង្គជំនុំជម្រះសាលាដំបូងនេះ។ នៅពេលច្រានចោលរឿងក្តី *កោះ Borkum* ដែលជាភស្តុតាងនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ អង្គជំនុំជម្រះសាលាដំបូងបានកត់សម្គាល់ថា ក្រៅពីមូលដ្ឋាននៃការសម្រេចឱ្យមានពិរុទ្ធភាព "*វិសាលភាព*ដែលចុងចោទត្រូវបានរកឃើញថាទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះអំពើដែលពុំបានប្រព្រឹត្តដោយគាត់ដោយខ្លួនឯងផ្ទាល់ក៏ពុំច្បាស់លាស់ដូចគ្នាយោងតាមសាលក្រមសម្រេចពិរុទ្ធភាពនោះ"[93]។

### *(ii) ភាពខុសគ្នារវាងច្បាប់ common law និងប្រព័ន្ធច្បាប់ស៊ីវិល*

37. ដូចបានលើកឡើងខាងលើពាក់ព័ន្ធនឹងរឿងក្តី *Martin Gottfried Weiss* សហព្រះរាជអាជ្ញាយោងលើយោបល់របស់ចៅក្រមយោធាអាមេរិក អំពីច្បាប់ស្តីពីគម្រោងរួម ដោយបានអះអាងថា យោបល់នេះគឺជាការប្រកាសទទួលស្គាល់នូវសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣[94]។ ទោះបីជាយ៉ាងនេះក្តី មតិយោបល់របស់ចៅក្រមយោធា ពុំមែនជាសាលក្រម ឬ ច្បាប់នោះទេ។ បើទោះជាមតិយោបល់នេះត្រូវបានចាត់ទុកជាសេចក្តីថ្លែងការណ៍ ដែលធ្វើឡើងដោយស្ថាប័នជាតិមួយដែលឆ្លុះបញ្ចាំងនូវ*ទស្សនៈច្បាប់*របស់សហរដ្ឋអាមេរិកក៏ដោយ ក៏មតិយោបល់មួយនេះដែលឆ្លុះបញ្ចាំងនូវជំហររបស់រដ្ឋតែមួយប៉ុណ្ណោះ ពុំគ្រប់គ្រាន់ក្នុងការបង្ហាញនូវអត្ថិភាពនៃវិធានច្បាប់ទំនៀមទម្លាប់

---

[91] *ខាងលើ* ត្រង់កថាខណ្ឌ ១៥។

[92] សាលដីកា *Tadić* កថាខណ្ឌ ១៩២។ *សូមមើល* Cassese, *International Criminal Justice* *ផងដែរ* ទំព័រ ៥៥។

[93] ឯកសារលេខ E100/6 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣០ (គូសបញ្ជាក់បន្ថែម)។

[94] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤០។

អន្តរជាតិនោះឡើយ ជាពិសេស ដោយហេតុថា ច្បាប់ស៊ីវិលខុសគ្នាខ្លាំងពីច្បាប់ខំមិនឡ (common law) នៅក្នុងតំបន់នេះ។

38. មេធាវីការពារក្តីកត់សម្គាល់ឃើញថា ទោះបីជាសហព្រះរាជអាជ្ញាបានដកស្រង់ដើម្បីគាំទ្រអំពីអត្ថិភាពនៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏យោបល់របស់ចៅក្រមយោធា សំដៅលើទស្សនទាននៃគម្រោងរួមថាជា "គោលការណ៍ច្បាប់ដែលត្រូវបានទទួលស្គាល់ត្រឹមត្រូវ"[95]។ ក៏ប៉ុន្តែក្រៅពីប្រភពបានមកពីការសិក្សាស្រាវជ្រាវទាំងពីរ (ដែលទំនងជាផ្អែកលើច្បាប់ព្រហ្មទណ្ឌក្នុងស្រុក) សេចក្តីថ្លែងការណ៍របស់ចៅក្រមយោធាពុំបានយោងលើឯកសារមូលដ្ឋានតាមផ្លូវច្បាប់ណាមួយនោះទេ[96]។ វាពុំបង្ហាញច្បាស់ថាតើ "គោលការណ៍ដែលត្រូវបានទទួលស្គាល់ត្រឹមត្រូវ" នេះសំដៅលើគោលការណ៍នៃច្បាប់សហរដ្ឋអាមេរិក ច្បាប់ខំមិនឡ ឬក៏ច្បាប់នៃប្រជាជាតិនៅលើពិភពលោកជារួម។ ទោះបីជាយ៉ាងនេះក៏ដោយ ដោយសារសេចក្តីថ្លែងការណ៍នេះលើកឡើងអំពី "គោលការណ៍" នោះ មេធាវីការពារក្តីនឹងឆ្លើយតបទៅនឹងចំណុចនេះទាក់ទងនឹងគោលការណ៍ទូទៅ។

39. វាការពិតដែលថា នៅក្នុងការជំនុំជម្រះលើរឿងក្តីក្នុងសម័យសង្គ្រាមលោកលើកទី II នៅចំពោះមុខតុលាការជាតិ ធាតុផ្សំមួយចំនួននៃច្បាប់ព្រហ្មទណ្ឌជាតិត្រូវបានដកស្រង់យកមកពន្យល់ជាឧទាហរណ៍អំពីទស្សនទាននៃ "ការធ្វើមនុស្សឃាត"[97] និងអំពីទម្រង់នៃការទទួលខុសត្រូវដូចជា "ការពាក់ព័ន្ធនឹងការកាប់សម្លាប់" និង "គម្រោងរួម"[98]។ វាពុំបង្ហាញច្បាស់ថាតើតុលាការជាតិទាំងនោះនឹងផ្តល់យុត្តិកម្មចំពោះការប្រើប្រាស់ច្បាប់ជាតិបែបនេះបានយ៉ាងដូចម្តេចនោះទេ ប៉ុន្តែនៅក្នុងមតិយោបល់របស់ UNWCC ការដកស្រង់ច្បាប់ជាតិបែបនេះពុំមានចេតនាដើម្បីយកអនុវត្តច្បាប់ជាតិ ឬយកមកជំនួសច្បាប់អន្តរជាតិនោះឡើយ ប៉ុន្តែគ្រាន់តែដើម្បីពង្រឹងច្បាប់អន្តរជាតិនៅក្រោមទ្រឹស្តីស្តីពីគោលការណ៍ទូទៅនៃប្រជាជាតិស៊ីវិល័យតែប៉ុណ្ណោះ[99]។ UNWCC គ្រាន់តែចង់បង្ហាញ

---

[95] 'Review of Proceedings of General Military Court in the Cases of United States v. Martin Weiss and Others' ("ការពិនិត្យមើលឡើងវិញរបស់ចៅក្រមអាមេរិក Advocate") ទំព័រ ១៤១ (*សូមមើល* F11.1.55 ERN 01041038)។

[96] ការពិនិត្យមើលឡើងវិញរបស់ចៅក្រមអាមេរិក Advocate" ទំព័រ ១៤១ (*សូមមើល* F11.1.55 ERN 01041038)។

[97] *The Jaluit Atoll Case*, US Military Commission, 7-13 Dec 1945, UNWCC, 'Law Reports of the Trials of War Criminals' វ៉ុល I ទំព័រ ៨០។

[98] ការជំនុំជម្រះ *Franz Schonfeld និងជនជាប់ចោទប្រាំបួននាក់ផ្សេងទៀត* តុលាការយោធាអង់គ្លេស ថ្ងៃទី ១១ ដល់ ថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៤៦ UNWCC 'Law Reports of the Trials of War Criminals' វ៉ុល XI ទំព័រ ៦៨-៧២។

[99] របាយការណ៍ច្បាប់របស់ UNWCC វ៉ុល I ទំព័រ ៨០។ របាយការណ៍ច្បាប់របស់ UNWCC វ៉ុល XI ទំព័រ ៧២។

បន្ថែមទៀតដោយពុំចាំបាច់ធ្វើការពិនិត្យឡើងវិញលើច្បាប់ជាតិរបស់ប្រទេសនានាថា "វិធាននៃច្បាប់អង់គ្លេសពាក់ព័ន្ធនឹងការសមគំនិតនៅក្នុងឧក្រិដ្ឋកម្ម [...] នឹងត្រូវបាន "រកឃើញនៅក្នុងផ្នែកសារធាតុនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល័យភាគច្រើន"[100]។

40. ពីព្រោះតែមានការលើកឡើងថា ទស្សនទាននៃច្បាប់ខំមិនឡូ ស្តីពី "គម្រោងរួម" គឺជាគោលការណ៍ច្បាប់ព្រហ្មទណ្ឌទូទៅនៃប្រជាជាតិលើពិភពលោក យោបល់របស់ចៅក្រមយោធាអាមេរិក និងយោបល់ខាងលើរបស់ UNWCC ពុំអាចចាត់ទុកថាជាសេចក្តីសន្និដ្ឋានមួយដែលពុំធ្វើឱ្យមានព្យសនកម្មនោះទេ។ ចំណុចនេះពុំមែនដោយសារតែចៅក្រម ឬ UNWCC ពុំបានសំអាងលើយោបល់របស់ពួកគេនៅក្នុងការសិក្សាស្ទង់មតិជាដុំកំភួននោះទេ ប៉ុន្តែវាដោយសារច្បាប់ស៊ីវិលក្នុងពេលដំណាលៗគ្នានោះមានសារធាតុខុសគ្នាយ៉ាងច្បាស់ពីច្បាប់ខំមិនឡូ។

41. ជាការពិតណាស់ ដូចបានលើកឡើងដោយចៅក្រមអាល្លឺម៉ង់ Otto Kranzbühler ដែលបានការពារជនជាប់ចោទម្នាក់ក្នុងចំណោមជនជាប់ចោទនានាផ្សេងទៀត នៅចំពោះមុខសាលាក្តីយោធាអន្តរជាតិ៖

> គ្មានការព្យាយាមណាមួយបានធ្វើឡើង តាមរយៈការបានដឹងអំពីអ្វីដែលអាចការពារបាននៅក្រោមច្បាប់អន្តរជាតិនោះទេ។ ជាក់ស្តែង ធម្មនុញ្ញមានចេតនាត្រឹមតែនាំយកចុងចោទមួយចំនួនមកជំនុំជម្រះ និងកាត់ទោសតែប៉ុណ្ណោះ។ ជាឧទាហរណ៍ ខ្ញុំបានយោងលើការពិភាក្សាដែលមានគោលបំណងបង្ហាញនូវទស្សនទានរបស់អាមេរិកលើការសមគំនិត ពោលគឺ ផែនការ ឬ គម្រោងរួមក្នុងការប្រព្រឹត្តអំពើព្រហ្មទណ្ឌ។ អ្នកចូលរួមមកពីប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងសន្និសីទមានការសង្ស័យខ្លាំងអំពីការដាក់បញ្ចូលទស្សនទានេះនៅក្នុងវិធាននៃធម្មនុញ្ញទីក្រុងឡុងដ៍ដែលពួកគេពុំបាន*ដឹង*។ ប៉ុន្តែ នៅពេលអំណះអំណាងបានលើកឡើងថា ប្រសិនបើគ្មានទស្សនទាននេះ បុរសដូច Schacht មិនអាចត្រូវបានសម្រេចឱ្យមានពិរុទ្ធភាពបាននោះទេ ទស្សនទាននេះត្រូវបានទទួលយកថាមានមូលដ្ឋានគ្រប់គ្រាន់មួយសម្រាប់ដាក់បញ្ចូលការសមគំនិតនៅក្នុងធម្មនុញ្ញទីក្រុងឡុងដ៍[101]។

យោបល់នេះមិនត្រឹមតែបញ្ជាក់ថា ទស្សនទាននៃច្បាប់ខំមិនឡូ ស្តីពីផែនការរួម ឬ គម្រោងរួម "ពុំឃើញមាន" នៅក្នុងច្បាប់ស៊ីវិលប៉ុណ្ណោះនោះទេ វាថែមទាំងផ្តល់ជាពន្លឺលើ ហេតុផលនៅពីក្រោយ

---

[100] របាយការណ៍ច្បាប់របស់ UNWCC វ៉ុល XI ទំព័រ ៧២។

[101] Otto Kranzbühler, 'Nuremberg Eighteen Years Afterwards', in Guénaël Mettraux ed., *Perspectives on the Nuremberg Trial* (2008) ទំព័រ ៤៣៦-៤៣៧ (គូសបញ្ជាក់បន្ថែម)។

ការចែងបញ្ចូលនៅក្នុងធម្មនុញ្ញទីក្រុងឡុងដ៏អំពីទស្សនទានបែបនេះ ដែលទោះក្នុងករណីណាក៏ដោយបានបង្កើតជាគោលការណ៍ទូទៅមួយ ដែលត្រូវបានទទួលស្គាល់ដោយប្រជាជាតិនៅលើពិភពលោក ពោលគឺ ដើម្បីសម្រេចឱ្យមនុស្សមួយចំនួនទទួលខុសត្រូវ។ ហេតុផលនេះ ដែលគាំទ្រលើហេតុផលរបស់សកម្មជនជ្រុលហួសហេតុនៅពីក្រោយការដាក់បញ្ចូលរបស់តុលាការ ICTY អំពីសហឧក្រិដ្ឋកម្មរួម គួរតែជាហេតុផលរារាំងការដាក់បញ្ចូលទស្សនទាននេះ។ វាការពិតដែរថា ទស្សនទាននៃគម្រោងរួមពុំបានកម្រិតត្រឹមតែការសមគំនិតប៉ុណ្ណោះនោះទេ។ ក៏ប៉ុន្តែ ភាពខុសគ្នារវាងប្រព័ន្ធច្បាប់ធំៗទាំងពីរនេះពុំបានកម្រិតត្រឹមតែសញ្ញាណចង្អៀតនៃការសមគំនិតនោះឡើយ។

42. យោងតាមមាត្រា ៤ នៃ *ច្បាប់ចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ១៩៩៤* ដែលបានផ្ដល់សមត្ថកិច្ចឱ្យទៅសាលាក្ដីយោធាបារាំងធ្វើការជំនុំជម្រះលើឧក្រិដ្ឋជនសង្គ្រាម[102]៖

> ក្នុងករណីដែលមនុស្សក្រោមបង្គាប់ត្រូវបានចោទប្រកាន់ជាអតិថារីនៃឧក្រិដ្ឋកម្មសង្គ្រាម ហើយប្រធានរបស់ខ្លួនមិនអាចត្រូវបានចោទប្រកាន់ជាអ្នកទទួលខុសត្រូវដូចគ្នា ពួកគេគួរត្រូវបានចាត់ទុកថាចារីបន្ទាប់បន្សំ ដរាបណាពួកគេបានរៀបចំ ឬអត់អោនចំពោះអំពើល្មើសរបស់បុគ្គលក្រោមបង្គាប់របស់ខ្លួន។

43. អត្ថបទនេះបង្ហាញច្បាស់ថា ច្បាប់បារាំងដែលអនុវត្តជាធរមានលើការជំនុំជម្រះឧក្រិដ្ឋកម្មសង្គ្រាមនៅពេលនោះបានបែងចែករវាង "ចារីដែដល់" និង "អ្នកសមគំនិត" ដែលរៀបចំ ឬ អត់អោនចំពោះឧក្រិដ្ឋកម្ម។ ច្បាប់នេះចែងជាក់លាក់ថា អ្នកសមគំនិតបែបនេះមិនអាចសម្រេចឱ្យទទួលខុសត្រូវដូចគ្នានឹងចារីនោះឡើយ។ ចំណុចនេះមានលក្ខណៈខុសគ្នាផ្នែកសារធាតុពីច្បាប់ខំមិនឡូ ដែលពុំបានបែងចែកតឹងរ៉ឹងពាក់ព័ន្ធនឹងការទទួលខុសត្រូវ និងការចោទប្រកាន់ បញ្ជូនរឿងទៅជំនុំជម្រះរវាងចារី និងអ្នកសមគំនិតនោះទេ។ ច្បាប់នេះអាចអនុវត្តបាននៅក្នុង គ្រប់ប្រទេសអាណានិគមនិយមរបស់បារាំងនាពេលនោះ[103] រួមទាំងប្រទេសកម្ពុជាផងដែរ។ ហេតុដូច្នេះ យោងតាមស្មារតីនៃគោលការណ៍នីត្យានុកូលភាព ច្បាប់នេះគួរយកចិត្តទុកដាក់ជាក់លាក់នៅក្នុងការវាយតម្លៃលើភាពអាចប្រមើលមើលបាននៃច្បាប់ចំពោះជនជាប់ចោទនៅក្នុងរឿងក្ដីបច្ចុប្បន្ន[104]។

---

[102] របាយការណ៍ច្បាប់របស់ UNWCC វ៉ុល III ឧបសម្ព័ន្ធ II ទំព័រ ៩៣-៩៤។

[103] របាយការណ៍ច្បាប់របស់ UNWCC វ៉ុល III ឧបសម្ព័ន្ធ II ទំព័រ ៩៣។

[104] *ខាងលើ* ត្រង់កថាខណ្ឌ ២៣។

44. យោងតាមចំណុចខាងលើនេះ វាងាយនឹងយល់បានថា សញ្ញាណនៃច្បាប់ខំមិនឡូ អំពី "គម្រោងរួម" ពុំមែនជាគោលការណ៍ទូទៅមួយទាល់តែសោះនៅក្នុងអំឡុងសម័យក្រោយសង្គ្រាមលោកលើកទី II។ ជាការពិតណាស់ បើទោះវាជាគោលការណ៍ទូទៅក៏ដោយ សញ្ញាណនេះពុំបានគាំទ្រលើទម្រង់នៃការទទួលខុសត្រូវលើសហឧក្រិដ្ឋកម្មរួមនោះទេ។ សញ្ញាណនេះនឹងយកមកពន្យល់នៅក្នុងចំណុចខាងក្រោម។

## ង. ច្បាប់ក្នុងស្រុក និងយុត្តិសាស្ត្រពុំគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី ៣ នៅក្នុងគោលការណ៍ទូទៅនៃប្រជាជាតិ

45. ដូចបានលើកឡើងខាងលើ[105] បើទោះជាទំនងគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិក៏ដោយ ក៏សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្តីពីច្បាប់ជាតិ[106] អាចត្រូវបានពិចារណានៅក្នុងន័យនៃគោលការណ៍ទូទៅតែប៉ុណ្ណោះ។

46. ជាយោបល់ទូទៅស្តីពីវិធីសាស្ត្រ មេធាវីការពារក្តីកត់សម្គាល់ឃើញថា ទោះបីជាការបង្កើតគោលការណ៍ទូទៅទាមទារនូវលក្ខខណ្ឌបទដ្ឋានមួយយ៉ាងខ្ពស់ក៏ដោយ ពោលគឺ ប្រទេស "ភាគច្រើន បើទោះមិនមែនទាំងអស់ក៏ដោយ" យល់ស្របលើសញ្ញាណរួមនេះ ក៏ការជំទាស់លើអត្ថិភាពនៃគោលការណ៍ទូទៅទាមទារឱ្យបង្ហាញតែភាពខុសគ្នាក្នុងចំណោមច្បាប់របស់ប្រទេសធំៗតែប៉ុណ្ណោះ។ នៅពេល "គោលការណ៍" ទាក់ទងនឹងច្បាប់ព្រហ្មទណ្ឌ គោលការណ៍នីត្យានុកូលភាពទាមទារថា ច្បាប់ជាតិរបស់ប្រទេសនានាដែលជាធម្មតាមានយុត្តាធិការលើឧក្រិដ្ឋកម្មនោះគួរយកចិត្តទុកដាក់ជាពិសេស។

### *(i) ច្បាប់ជាតិរបស់ប្រទេសមហាអំណាចចំនួន ៦ និងច្បាប់កម្ពុជាដែលត្រូវបានពិនិត្យមើលឡើងវិញដោយអង្គជំនុំជម្រះសាលាដំបូង*

47. សហព្រះរាជអាជ្ញាយោងលើច្បាប់ជាតិរបស់ប្រទេសចំនួន ៤០ ក្នុងនោះប្រទេសចំនួនប្រាំពីរត្រូវបានពិនិត្យមើលឡើងវិញយ៉ាងប្រុងប្រយ័ត្នដោយអង្គជំនុំជម្រះសាលាដំបូង។ ប្រទេសទាំងប្រាំពីរនេះរួមបញ្ចូលទាំងប្រព័ន្ធច្បាប់ជាតិរបស់ប្រទេសធំៗចំនួនប្រាំមួយ (ចក្រភពអង់គ្លេស សហរដ្ឋ

---

[105] *ខាងលើ* ត្រង់កថាខណ្ឌ ១៨-១៩។

[106] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥០-៥៧។

អាមេរិក អាល្លឺម៉ង់ សហភាពសូវៀត ប្រទេសបារាំង និងប្រទេសហូឡង់ដ៏) និងប្រទេសកម្ពុជា។ ផ្អែកតាមការពិនិត្យមើលឡើងវិញនេះ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា វាមាន "ភាពខុសពីគ្នាជាច្រើនអំពីវិធីសាស្ត្រ" ក្នុងចំណោមច្បាប់ជាតិរបស់ប្រទេសចំនួនប្រាំពីរនេះ ហើយច្បាប់ជាតិស្តីពីកម្មវត្ថុនៅចំពោះមុខ "មិនមានការឯកភាពគ្នាឲ្យបានគ្រប់គ្រាន់ដើម្បីចាត់ទុកថា វាជាគោលការណ៍ទូទៅនៃច្បាប់" នោះឡើយ[107]។ ម្យ៉ាងវិញទៀត សំអាងហេតុជាក់លាក់របស់អង្គជំនុំជម្រះសាលាដំបូងលើប្រទេសនីមួយៗក្នុងចំណោមប្រទេសទាំងនេះក៏បញ្ជាក់ផងដែរថា ផ្ទុយពីការអះអាងរបស់សហព្រះរាជអាជ្ញា ច្បាប់របស់ប្រទេសចំនួនប្រាំមួយក្នុងចំណោមប្រទេសទាំងប្រាំពីរ (ប៉ុន្តែ មិនមែនសហរដ្ឋអាមេរិក) នៅក្នុងអំឡុងពេលពាក់ព័ន្ធ មានចែងច្បាស់លាស់ - បើទោះជាមានភាពខុសគ្នាជាក់លាក់ក៏ដោយ - ថា បើទោះនៅក្នុងរឿងក្តីនៃឧក្រិដ្ឋកម្មរួមគ្នា ការទទួលខុសត្រូវរបស់បុគ្គលម្នាក់មិនអាចពង្រីកដល់ឧក្រិដ្ឋកម្មនៅក្រៅគម្រោង ឬចេតនាដែលបានយល់ស្របគ្នានោះទេ[108]។ ពាក់ព័ន្ធនឹងសហរដ្ឋអាមេរិក អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានថា ទស្សនទានពាក់ព័ន្ធបំផុតនៅក្នុងច្បាប់របស់ប្រទេសនេះគឺ "ការសមគំនិត" ដែលមានលក្ខណៈជាក់លាក់ចំពោះប្រព័ន្ធច្បាប់នេះ ហើយត្រូវបានចាត់ទុកថាជា "បទល្មើសមួយដោយឡែក" ពុំមែនទម្រង់នៃការទទួលខុសត្រូវនោះឡើយ[109]។ បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាខកខានពុំបានផ្តល់ព័ត៌មានថ្មីណាមួយស្តីពីច្បាប់ជាតិរបស់ប្រទេសទាំងនេះ ដែលអាចមានលក្ខណៈគ្រប់គ្រាន់អាចច្រានចោលសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងនោះទេ។ មេធាវីការពារក្តីនឹងឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានខ្លះៗរបស់សហព្រះរាជអាជ្ញានៅក្នុងករណីនេះ។

48. ***ប្រទេសហូឡង់ដ៏៖*** ពាក់ព័ន្ធនឹងប្រទេសហូឡង់ដ៏ សហព្រះរាជអាជ្ញាអះអាងថា អង្គជំនុំជម្រះសាលាដំបូងខកខានមិនបានពិចារណាមាត្រា ៤៧(១) មាត្រា ៣០០ មាត្រា ៣០២ និងមាត្រា ៣១២ នៃច្បាប់ព្រហ្មទណ្ឌហូឡង់ដ៏[110]។ ទោះបីជាយ៉ាងនេះក្តី មាត្រា ៤៧ គឺគ្រាន់តែជាមាត្រាទូទៅ

[107] ឯកសារលេខ E100/6 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧ (លេខយោងជើងទំព័រ ៨៥-៩១)។

[108] ឯកសារលេខ E100/6 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧ (លេខយោងជើងទំព័រ ៨៥ ទំព័រ ៨៧-៩១)។

[109] ឯកសារលេខ E100/6 សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសហឧក្រិដ្ឋកម្មរួម កថាខណ្ឌ ៣៧ (លេខយោងជើងទំព័រ ៨៦)។

[110] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦។

មួយស្តីពីការទួលខុសត្រូវដែលចែងអំពីចារីកម្ម សហចារីកម្ម និងការញុះញង់។ វាពុំគាំទ្រអត្ថិភាពនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ឡើយ។ ម្យ៉ាងវិញទៀត មាត្រា ៤៧ នេះចែងជាក់លាក់ថា ការទទួលខុសត្រូវរបស់អ្នកញុះញង់*ពុំ*ពង្រីកដល់ឧក្រិដ្ឋកម្មនៅក្រៅការញុះញង់នោះឡើយ។ មេធាវីការពារក្តីកត់សម្គាល់ផងដែរថា មាត្រា ៤៨ នៃក្រមព្រហ្មទណ្ឌហ្វូឡង់ដ៏ ដែលសហព្រះរាជអាជ្ញាមិនបានយោងនោះមានចែងអំពីការសមគំនិត។ ការសមគំនិតនេះមានចែងជាក់លាក់នៅក្នុងមាត្រា ៤៨ ថា ការសមគំនិតកម្រិតត្រឹមបទឧក្រិដ្ឋតែប៉ុណ្ណោះ ហើយបុគ្គលម្នាក់អាចត្រូវបានសម្រេចឱ្យទទួលខុសត្រូវតាមរយៈការសមគំនិតនេះបាន ប្រសិនបើខ្លួនចូលរួមចំណែក*ដោយចេតនា*លើបទឧក្រិដ្ឋដែលបានប្រព្រឹត្តឡើងដោយបុគ្គលដទៃ។ ហេតុដូច្នេះ ផ្ទុយពីការចោទប្រកាន់របស់សហព្រះរាជអាជ្ញា តាមពិត មាត្រាទាំងនេះគូសបញ្ជាក់ថា ច្បាប់ហូឡង់ដ៍ពុំគាំទ្រសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នោះទេ។ មេធាវីការពារក្តីនឹងពុំឆ្លើយតបទៅនឹងមាត្រា ៣០០ មាត្រា ៣០២ និងមាត្រា ៣១២ ដោយសារវាពុំពាក់ព័ន្ធយ៉ាងច្បាស់លាស់។

49. ***ប្រទេសអាល្លឺម៉ង់៖*** សហព្រះរាជអាជ្ញាអះអាងថា យុត្តិសាស្ត្ររបស់ប្រទេសអាល្លឺម៉ង់នៅក្រោយរឿងក្តីនេះដែលបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងបង្ហាញថា យ៉ាងហោចណាស់ចាប់ពីឆ្នាំ ១៩៦៧ មក ច្បាប់អាល្លឺម៉ង់បានទទួលស្គាល់អំពី "ការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មដោយចេតនារបស់ក្រុម ប៉ុន្តែអាចព្យាករណ៍បាន"[111]។ ទោះបីជាយ៉ាងនេះក៏ដោយ រឿងក្តីថ្មីចំនួនពីរដែលបានយោងដោយសហព្រះរាជអាជ្ញា[112] ហាក់ដូចជាពុំច្រានចោលរឿងក្តីដែលបានសំអាងដោយអង្គជំនុំជម្រះសាលាដំបូងដែលបានសម្រេចថា ការទទួលខុសត្រូវនៅក្នុងឧក្រិដ្ឋកម្មរួមពុំពង្រីករហូតដល់អំពើដែលបានប្រព្រឹត្តជ្រុលហួស នៅក្រៅសេចក្តីសម្រេចរួមរបស់ពួកគេនោះទេ[113]។ ជាងនេះទៀត រឿងក្តីមួយក្នុងចំណោមរឿងក្តីទាំងពីរនេះគឺរឿងក្តីស្តីពីការខូចខាតផ្ទៃករដ្ឋប្បវេណី[114] ហើយ

---

[111] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦។

[112] ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦ លេខយោងជើងទំព័រ ១៧៨ ដែលដកស្រង់ BGH 17.03 (1967) (សូមមើល ឯកសារលេខ F11.1.88) និង BGH 11.05 (1971)-VI ZR 211/69 (សូមមើល ឯកសារលេខ F11.1.89)។

[113] RGSt 44, 321 "Die erforderlichkeit eines gemeinsamen Tatentschluss schliesst die Möglichkeit der gegenseitigung von Exzesstaten aus." ដូចបានដកស្រង់នៅក្នុង Vojislav Damnjanović, *Die Beteiligungsformen im deutschen und serbischen Strafrecht sowie in der ICTY-Rechtsprechung* (2013)ទំព័រ ៤៣។

[114] BGH 11.05 (1971)-VI ZR 211/69 ដូចបានដកស្រង់នៅក្នុង ឯកសារលេខ F11 បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦ លេខយោងជើងទំព័រ ១៧៨ (សូមមើល ឯកសារលេខ F11.1.89)។

បទដ្ឋាននៅក្នុងរឿងក្ដីស្ដីពីការខូចខាតរដ្ឋប្បវេណី មិនអាចប្រដូចនឹងបទដ្ឋាននៅក្នុងរឿងក្ដីព្រហ្មទណ្ឌនោះឡើយ។

50. ***ប្រទេសកម្ពុជា៖*** សហព្រះរាជអាជ្ញាក៏អះអាងថា វាមានមូលដ្ឋានសម្រាប់សហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ នៅក្នុងច្បាប់កម្ពុជាដោយបានយោងលើមាត្រា ១៤៥ និងមាត្រា ២៣១ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦[115]។ ទោះបីជាយ៉ាងនេះក្ដី មាត្រា ១៤៥ គ្រាន់តែចែងថា វាអាចមានឧក្រិដ្ឋកម្ម ដែលត្រូវបានប្រព្រឹត្តឡើងដោយមនុស្សច្រើននាក់ដែល "*បានមូលមាត់គ្នា*ថានឹងប្រព្រឹត្តបទល្មើសណាមួយជាមួយគ្នា ដោយខ្លះជា*សហការីក្ដី* ឬជា*អ្នកចូលគំនិតដោយជួយទំនប់បំរុងក្ដី*" (គូសបញ្ជាក់បន្ថែម)។ មាត្រានេះពុំចង្អុលបញ្ជាក់ថា ការទទួលខុសត្រូវអាចលាតសន្ធឹងរហូតដល់ប្រព្រឹត្តិនៅក្រៅអ្វីដែលបានយល់ស្របនឹងគ្នា ឬអ្នកទាំងឡាយដែលជាប់ពាក់ព័ន្ធត្រូវតែសម្រេចឲ្យទទួលខុសត្រូវក្នុងនាមជា "ចារី" ជាជាង "អ្នកសមគំនិត" នោះឡើយ។ មាត្រា ២៣១ បញ្ញត្តិអំពីបទល្មើសជាក់លាក់មួយដែលអនុវត្តតែចំពោះ "កុប្បកម្ម" ដោយ "ពួកក្រុម"។ គ្មានមាត្រាណាមួយនៃមាត្រាទាំងនេះដែលគាំទ្រទ្រឹស្ដីនៃសហឧក្រិដ្ឋកម្មរួមទម្រង់ទី៣ នោះឡើយ។

51. នៅក្នុងន័យនេះ មេធាវីការពារក្ដីសូមរំលឹកដល់អង្គជំនុំជម្រះនេះថា ដូចបានកត់សម្គាល់ខាងលើ[116] ច្បាប់ឆ្នាំ ១៩៤៤ របស់ប្រទេសបារាំងទាក់ទងនឹងការជំនុំជម្រះឧក្រិដ្ឋជនសង្គ្រាមក៏អាចអនុវត្តបានចំពោះប្រទេសកម្ពុជាផងដែរ នៅពេលនោះគឺជាប្រទេសក្រោមអាណានិគមនិយមបារាំង។ មាត្រា ៤ នៃច្បាប់នេះលើកឡើងថា ទម្រង់នៃការទទួលខុសត្រូវដែលមានចែងនៅក្នុងច្បាប់នោះគឺខុសពីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣។

52. ដោយហេតុថាគ្មានព័ត៌មានណាមួយ បង្ហាញនៅក្នុងបណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាអាចឲ្យច្រានចោលការពិនិត្យឡើងវិញជាលម្អិតរបស់អង្គជំនុំជម្រះសាលាដំបូង លើច្បាប់ជាតិរបស់ប្រទេសទាំងប្រាំពីរនេះ វាពុំចាំបាច់ងាកចេញពីសំអាងហេតុរបស់អង្គជំនុំជម្រះសាលាដំបូងថា វាពុំមានភាពស៊ីសង្វាក់គ្នាគ្រប់គ្រាន់អាចបង្ហាញនូវគោលការណ៍ទូទៅមួយ ដើម្បីគាំទ្រសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣។ ដោយហេតុថា ការជំទាស់នឹងគោលការណ៍ទូទៅគ្រាន់តែជាការស្នើសុំឲ្យបង្ហាញនូវភាពខុសគ្នាក្នុងចំណោមប្រទេសធំៗមួយចំនួនប៉ុណ្ណោះ ហេតុដូច្នេះ វាពុំចាំបាច់

[115] ឯកសារលេខ F11 បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦ លេខយោងជើងទំព័រ ១៨០។

[116] *ខាងលើ* កថាខណ្ឌ ៤២-៤៣។

ពិនិត្យមើលបន្ថែមនៅក្នុងច្បាប់របស់ប្រទេសចំនួន ៣៣ ដែលនៅសេសសល់ដូចបានយោងដោយសហព្រះរាជអាជ្ញានោះឡើយ។ ទោះជាយ៉ាងណាក៏ដោយ មេធាវីការពារក្ដីនឹងឆ្លើយតបដោយចោះៗចំពោះទិដ្ឋភាពខ្លះៗនៃសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានៅក្នុងករណីនេះ។

### *(ii) ច្បាប់ជាតិរបស់ប្រទេសចំនួន ៣៣ ផ្សេងទៀតដែលបានដកស្រង់ដោយសហព្រះរាជអាជ្ញា*

53. សហព្រះរាជអាជ្ញាទទួលស្គាល់ថា ច្បាប់ជាតិរបស់ប្រទេសចំនួន ១៨ ក្នុងចំណោមប្រទេសចំនួន ៤០ ដែលពួកគាត់បានពិនិត្យមើលឡើងវិញ (រួមទាំង ប្រទេសកម្ពុជា ប្រទេសអាល្លឺម៉ង់ ប្រទេសអង់គ្លេស និងអតីតប្រទេសសូវៀត) *ពុំ* "បានពង្រីកយ៉ាងច្បាស់លាស់នូវការទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្ម ដែលអាចប្រមើលមើលឃើញនៅក្រៅផែនការរួម" នោះទេ[117]។ ក៏ប៉ុន្តែ សហព្រះរាជអាជ្ញាអះអាងថា បើទោះជាមានលក្ខណៈដោយឡែកពីគ្នាក៏ដោយ ច្បាប់ជាតិរបស់ប្រទេសចំនួន ១៨ បានទទួលស្គាល់ទាំងអស់គ្នាអំពីឧក្រិដ្ឋកម្មជាក្រុម និងការដាក់ឲ្យទទួលខុសត្រូវចំពោះអំពើឆ្វេសប្រហែស (នៅក្នុងឧក្រិដ្ឋកម្មមិនមែនជាក្រុម)។ សហព្រះរាជអាជ្ញាអះអាងថា នៅពេលអានផ្គួបជាមួយគ្នា សញ្ញាណទាំងពីរនេះបង្កើតជាមូលដ្ឋាននៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣។ ទោះបីជាយ៉ាងនេះក៏ដោយក្ដី ករណីដែលថា ទស្សនទានទាំងពីរនេះមានអត្ថិភាពដោយឡែកពីគ្នាពុំមានន័យថា ការច្របាច់បញ្ចូលគ្នារវាងទស្សនទានទាំងពីរក៏មានអត្ថិភាពដូចគ្នាលើកលែងតែមានចែងជាក់លាក់នៅក្នុងច្បាប់លើករណីនេះតែម្ដង។ ទោះក្នុងករណីណាក៏ដោយ ការពង្រីកការទទួលខុសត្រូវតាមរយៈការប្រៀបធៀប គឺផ្ទុយនឹងគោលការណ៍នីត្យានុកូលភាព។ ទទ្បីករណ៍បន្ថែមរបស់សហព្រះរាជអាជ្ញាទាក់ទងនឹង "ស្ពានទម្ងន់នៅក្នុងការដាក់ទោស" ក៏ពុំពាក់ព័ន្ធ និងពុំមានលក្ខណៈជាក់ស្ដែងផងដែរ។ ដូច្នេះ មេធាវីការពារក្ដីនឹងពុំឆ្លើយតបទៅនឹងផ្នែកសារធាតុនៃច្បាប់ជាតិរបស់ប្រទេសទាំង ១៨ នេះឡើយ។

54. សហព្រះរាជអាជ្ញាអះអាងថា ប្រទេសចំនួន ២៣ ក្នុងចំណោមប្រទេសចំនួន ៤០ (រួមទាំងប្រទេសបារាំង និងសហរដ្ឋអាមេរិក) គាំទ្រយ៉ាងច្បាស់លាស់លើសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ [118]។ ក៏ប៉ុន្តែ ការអះអាងនេះពុំពិតនោះឡើយ។ ហេតុផលទីមួយ ប្រទេសទាំងនេះពុំបានបែងចែករវាងអតិចារី និងចារីបន្ទាប់បន្សំទាក់ទងនឹងកម្រិតនៃការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ពួកគេ ឬ

---

[117] ឯកសារលេខ F11 បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៣។

[118] ឯកសារលេខ F11 បណ្ដឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥២។

ទោះបីជានៅពេលប្រទេសទាំងនេះបែងចែកក៏ដោយ ក៏ការទទួលខុសត្រូវដូចសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ត្រូវបានចាត់ទុកត្រឹមតែជា*ចារីបន្ទាប់បន្សំ* (ខុសពីការទទួលខុសត្រូវចម្បងរបស់ចារី)។ ឧទាហរណ៍ យុត្តិសាស្ត្ររបស់ប្រទេសណូវែហ្សេឡង់ដ៏ចែងច្បាស់ថា នៅក្នុង "សហឧក្រិដ្ឋកម្មរួម" បុគ្គលទាំងឡាយដែលត្រឹមតែអាចប្រមើលមើលឃើញថា ឧក្រិដ្ឋកម្មមួយអាចនឹងប្រព្រឹត្តឡើង ដោយ "អតិចារី" ត្រូវបានចាត់ទុកថាជា "ចារីបន្ទាប់បន្សំ" ហើយអាចសម្រេចឲ្យទទួលខុសត្រូវ ចំពោះ "ការទទួលខុសត្រូវរបស់ចារីបន្ទាប់បន្សំ" តែប៉ុណ្ណោះ[119]។ មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌអ៊ីរ៉ាក់ ឆ្នាំ១៩៦៩ ក៏ចែងច្បាស់ផងដែរថា "ចារីនៃបទល្មើស" អាចជា "អតិចារី" ឬ "ចារីបន្ទាប់បន្សំ"។

55. លើសពីនេះ យ៉ាងហោចណាស់មានប្រទេសចំនួនពីរ (ប្រទេសអ៊ីរ៉ាក់[120] និងប្រទេសអ៊ីតាលី[121]) ដែលកម្រិតការទទួលខុសត្រូវរបស់បុគ្គលចំពោះឧក្រិដ្ឋកម្មដែលអាចប្រមើលមើលឃើញ បើទោះបីជាគ្មានចេតនាក៏ដោយក្តីចំពោះឧក្រិដ្ឋកម្មទាំងឡាយណាដែលជាផលវិបាកនៃអំពើសកម្ម ឬអំពើសកម្មរបស់បុគ្គលម្នាក់ជាជាងអំពើរបស់សមាជិកផ្សេងទៀតនៅក្នុងក្រុម។ ផ្នែក ២៤ នៃក្រមច្បាប់ព្រហ្មទណ្ឌរបស់ប្រទេសអ៊ីស្រាអែលឆ្នាំ ១៩៣៦ ចែងជាក់លាក់ថា មានតែ "បុគ្គលដែលមាន*វត្តមាន*នៅពេលប្រព្រឹត្ត" តែប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថាបានប្រព្រឹត្តឧក្រិដ្ឋកម្មជ្រុលហួស ប៉ុន្តែអាចប្រមើលមើលឃើញបាន (ការគូសបញ្ជាក់បន្ថែម)។

56. ចំណុចខុសគ្នាខាងលើរវាងច្បាប់ជាតិ និងទ្រឹស្តីនៃសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ពុំចាត់ទុកជាការចែងរៀបរាប់លម្អិតទាំងអស់នោះទេ។ ក៏ប៉ុន្តែ សម្រាប់គោលបំណងនៃការជំទាស់លើអត្ថិភាពនៃគោលការណ៍ទូទៅ ចំណុចខុសគ្នាទាំងនេះឃើញមានហួសពីភាពគ្រប់គ្រាន់ទៅទៀត។

### *(iii) សហចារីកម្ម គម្រោងរួម និងសហឧក្រិដ្ឋកម្មរួម*

57. បន្ថែមលើការវិភាគខាងលើ មេធាវីការពារក្តីក៏សូមលើកយោបល់ទូទៅខ្លះស្តីពីភាពខុសគ្នារវាង

---

[119] រឿងក្តី *R ទល់នឹង Tauaalo និង Alovili* [2008] NZHC 1099 21-23 (សូមមើល ឯកសារលេខ F11.1.116)។

[120] ក្រមព្រហ្មទណ្ឌអ៊ីរ៉ាក់ឆ្នាំ ១៩៦៩ មាត្រា ៥៣ "ដរាបណាបទល្មើសដែលត្រូវបានប្រព្រឹត្តប្រាកដថាទំនងជាផលវិបាកនៃការចូលរួមរបស់*គាត់*នៅក្នុងបទល្មើសនេះ" (សូមមើល ឯកសារលេខ F11.1.97)។ (គូសបញ្ជាក់បន្ថែម)។

[121] ក្រមព្រហ្មទណ្ឌអ៊ីតាលីឆ្នាំ ១៩៣០ មាត្រា ១១៦ "ប្រសិនបើឧក្រិដ្ឋកម្មគឺជាផលវិបាកនៃអំពើសកម្ម ឬ អំពើអកម្មរបស់*គាត់*" (សូមមើល ឯកសារលេខ F11.1.101)។ (គូសបញ្ជាក់បន្ថែម)។

ទស្សនទាននៃច្បាប់ស៊ីវិលស្តីពី “សហចារីកម្ម” ទស្សនទាននៃច្បាប់ខំមិនឡូ ស្តីពី “គម្រោងរួម” ជាមួយនឹងទស្សនទាននៃសហឧក្រិដ្ឋកម្មរួម។ ចំណុចទីមួយ សហចារីកម្មត្រូវបានទទួលស្គាល់នៅស្ទើរតែគ្រប់ច្បាប់ស៊ីវិល ដូចជា ប្រទេសបារាំង ប្រទេសអាល្លឺម៉ង់ ប្រទេសហូឡង់ដ៏ និងប្រទេសកម្ពុជា[122]។ ភាពខុសគ្នាខ្លាំងបំផុតរវាងសហចារីកម្ម និងសហឧក្រិដ្ឋកម្មរួមគឺថា សហចារីកម្មតម្រូវលក្ខខណ្ឌនៃការចូលរួមចំណែក *ជាដុំកំភួនដែលពុំអាចខ្វះបាន* របស់សហចារីចំពោះឧក្រិដ្ឋកម្ម ប៉ុន្តែសហឧក្រិដ្ឋកម្មរួមទាមទារតែការចូលរួមចំណែក “សំខាន់” ប៉ុន្តែពុំចាំបាច់ជាការរួមចំណែកដុំកំភួននោះទេ[123]។ ចំណុចនេះក៏ជាភាពខុសគ្នាធំមួយរវាងសហចារីកម្ម និងគម្រោងរួម។ ទោះបីជាយ៉ាងនេះក៏ដោយក្តី គម្រោងរួមមក៏ខុសគ្នាជាដុំកំភួនពីសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ផងដែរ ពីព្រោះថា *ក្នុងនោះ* ទ្រឹស្តីស្តីពីការធ្វេសប្រហែសនៅក្នុងច្បាប់ខំមិនឡូ ទាមទារនូវលក្ខខណ្ឌថា ផលវិបាកដែលអាចប្រមើលមើលឃើញពុំចាំបាច់តែ “អាចកើតឡើងប្រាកដ” (ខុសពី “លទ្ធភាពដែលអាចកើតឡើង”) ប៉ុន្តែក៏អាចជាហានិភ័យ “ពុំសមហេតុផល” និង “ពុំមានយុត្តិកម្ម” ចំណែកសហឧក្រិដ្ឋកម្មរួម ទម្រង់ទី៣ ពុំទាមទារនូវលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងពីរនេះទេ[124]។

## III. សំណើ

58. យោងតាមហេតុផលដូចបានលើកឡើងខាងលើ មេធាវីការពារក្តីស្នើសុំឱ្យអង្គជំនុំជម្រះតុលាការកំពូល៖

(ក) ប្រកាសថា បណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញាពុំអាចទទួលយកបាន និង

(ខ) ច្រានចោលបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា។

---

[122] ក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ ១៩៥៦ មាត្រា ៨២ “ការចូលរួមដោយផ្ទាល់ចាត់ទុកជាសហចារី ការចូលរួមដោយប្រយោលចាត់ទុកជាការសមគំនិត”។

[123] *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Gacumbitsi* មតិយោបល់ដោយឡែករបស់ចៅក្រម Shahabuddeen ចំពោះសាលដីកា រឿងក្តីលេខ ICTR-01-64-A ចុះថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ២០០៦ កថាខណ្ឌ ៥០។

[124] *សូមមើល ឧ.* រឿងក្តី *រដ្ឋអាជ្ញា ទល់នឹង Blaškić* “សាលដីកា” រឿងក្តីលេខ IT-95-14-A ចុះថ្ងៃទី ២៩ ខែ កក្កដា ឆ្នាំ២០០៤ កថាខណ្ឌ ៣៣ (សហឧក្រិដ្ឋកម្មរួមទាមទារនូវលក្ខខណ្ឌនៃ “ផលវិបាកដែលអាចកើតមានជាជាងលទ្ធភាពដែលអាចកើតមានជាដុំកំភួន”) កថាខណ្ឌ ៣៤-៣៥ កថាខណ្ឌ ៣៨។

សហមេធាវីការពារក្ដី នួន ជា

| | |
|---|---|
| សុន អរុណ | Victor KOPPE |